សៀវភៅណែនាំអំពីការស្នើរសុំប្រាក់ធានារ៉ាប់រងគ្រោះថ្នាក់ការងារ
< ភាគទី២ >

អំពីការឧបត្ថម្ភធានារ៉ាប់រងគ្រោះថ្នាក់ការងារ
ខ្លឹមសារនៃធានារ៉ាប់រងគ្រោះថ្នាក់ការងារគ្រប់ប្រភេទ

ការធានារ៉ាប់រងគ្រោះថ្នាក់ការងារ ត្រូវបានគេអនុវត្តន៍ចំពោះគ្រប់ជនជាតិទាំងអស់ដែលធ្វើការនៅប្រទេសជប៉ុន។ ចំពោះអ្នកដែលមានវិសាការងារ គឺប្រាកដណាស់ ហើយអ្នកដែលជានិស្សិតដែលកំពុងសិក្សាហើយមានគ្រោះថ្នាក់ពេលធ្វើការងារក្រៅម៉ោងក៏ដូចគ្នាដែរ។ សៀវភៅនេះធ្វើការពន្យល់អំពីប្រភេទនិងខ្លឹមសារនៃការឧបត្ថម្ភចំពោះធានារ៉ាប់រងគ្រោះថ្នាក់ការងាររបស់អ្នកធ្វើការជនជាតិបរទេស។

ចំពោះសេចក្តីលំអិតនៃលក្ខខណ្ឌនៃការផ្តល់ការឧបត្ថម្ភ សូមធ្វើការសាកសួរទៅការិយាល័យស្តង់ដារការងារ។

ហើយក៏មានការឧបត្ថម្ភខ្លះមិនអាចទទួលបានវិញដែរក្នុងករណីត្រឡប់ទៅប្រទេសវិញ សូមប្រុងប្រយ័ត្ន។

[មាតិកា]

ទិដ្ឋភាពទូទៅនៃការឧបត្ថម្ភធានារ៉ាប់រងគ្រោះថ្នាក់ការងារ • • • • P 2
ប្រាក់ឧបត្ថម្ភ(សំណង)ព្យាបាលជាដើម • • • • • • • • • • • • • • P14
ប្រាក់ឧបត្ថម្ភ(សំណង)ឈប់សម្រាកជាដើម • • • • • • • • • • • • P16
សោធន៍និវត្តន៍(សំណង) របួសនិងជំងឺជាដើម • • • • • • • • • • P17
ប្រាក់ឧបត្ថម្ភ(សំណង)ពិការភាពជាដើម • • • • • • • • • • • • • P18
ប្រាក់ឧបត្ថម្ភ(សំណង)គ្រួសារជាដើម
ប្រាក់ធ្វើបុណ្យសពជាដើម(ប្រាក់ឧបត្ថម្ភរៀបចំបុណ្យសព) • • • • • P26
ប្រាក់ឧបត្ថម្ភ(សំណង)សម្រាប់ការថែទាំជាដើម • • • • • • • • • • P33
តំរូបំពេញ • P36

ផ្នែកសំណងនៃការិយាល័យស្តង់ដារការងាររបស់ក្រសួងសង្គមកិច្ច
និងការងារ

ទិដ្ឋភាពទូទៅនៃការឧបត្ថម្ភធានារ៉ាប់រងគ្រោះថ្នាក់ការងារ

ធានារ៉ាប់រងគ្រោះថ្នាក់ការងារ ជាប្រព័ន្ធផ្តល់ការឧបត្ថម្ភធានារ៉ាប់រងសំរាប់ការព្យាបាល។ល។ នៅពេលដែលអ្នកធ្វើការមានរបួស មានជំងឺ ឬស្លាប់ដោយសារការធ្វើការឬធ្វើដំណើរទៅមកពីធ្វើការ។ ទោះជាជនបរទេសក៏ដោយ អោយតែធ្វើការនៅប្រទេសជប៉ុន គឺស្ថិតក្នុងក្របខ័ណ្ឌធានារ៉ាប់រងគ្រោះថ្នាក់ការងារនេះ។



*ចំពោះគ្រោះថ្នាក់ការងារ មិនអាចប្រើប្រាស់ធានារ៉ាប់រងសុខភាពបានទេ។

ប្រភេទប្រាក់ឧបត្ថម្ភនៃធានារ៉ាប់រងគ្រោះថ្នាក់ការងារ

- ◆ ប្រាក់ឧបត្ថម្ភ(សំណង)ព្យាបាលជាដើម : ការឧបត្ថម្ភផ្តល់នៅពេលទទួលការព្យាបាលរបួសឬជំងឺដោយសារការធ្វើដំណើរទៅមកពីធ្វើការ។
- ◆ ប្រាក់ឧបត្ថម្ភ(សំណង)ឈប់សម្រាកជាដើម : ប្រាក់ឧបត្ថម្ភផ្តល់នៅពេលទទួលការព្យាបាលរបួសឬជំងឺដោយសារការធ្វើការ ឬធ្វើដំណើរទៅមកពីធ្វើការ ហើយមិនអាចធ្វើការបាន និងមិនអាចទទួលកំរៃបាន។
- ◆ សោធន៍និវត្តន៍(សំណង)របួសនិងជំងឺជាដើម : ប្រាក់ឧបត្ថម្ភផ្តល់នៅពេលការព្យាបាលរបួសឬជំងឺដោយសារការធ្វើការ ឬធ្វើដំណើរទៅមកពីធ្វើការ ហើយក្រោយពីទទួលការព្យាបាល1ឆ្នាំ6ខែកន្លងទៅ របួសឬជំងឺមិននៅនឹង(អាការរោគលែងប្រែប្រួល) ហើយមានពិការភាពក្នុងកម្រិតស្របតាមកំរិតរបួសនិងជំងឺ។
- ◆ ប្រាក់ឧបត្ថម្ភ(សំណង)ពិការភាពជាដើម : ប្រាក់ឧបត្ថម្ភផ្តល់នៅពេលការព្យាបាលរបួសឬជំងឺដោយសារការធ្វើការឬធ្វើដំណើរទៅមកពីធ្វើការ បាននៅនឹង(អាការរោគលែងប្រែប្រួល) ហើយនៅសល់ពីការភាពលើរាងកាយក្នុងកម្រិតពិការភាព។
- ◆ ប្រាក់ឧបត្ថម្ភ(សំណង)គ្រួសារជាដើម: អត្ថប្រយោជន៍នៅពេលកម្មករស្លាប់ដោយសារការងារ ឬការធ្វើដំណើរ។
- ◆ ប្រាក់ធ្វើបុណ្យសពជាដើម(ប្រាក់ឧបត្ថម្ភសម្រាប់ធ្វើបុណ្យសព): អត្ថប្រយោជន៍ដែលចំណាយលើពិធីបុណ្យសពនៅពេលកម្មករស្លាប់ដោយសារការងារ ឬការធ្វើដំណើរ។
- ◆ ប្រាក់ឧបត្ថម្ភ(សំណង)សម្រាប់ការថែទាំជាដើម : សំណងផ្តល់នៅពេលទទួលសោធន៍និវត្តន៍(សំណង)អ្នកដែលមានពិការភាពជាដើម ឬសោធន៍និវត្តន៍(សំណង)របួសនិងជំងឺជាដើម ដែលមានពិការភាពហើយកំពុងទទួលការថែទាំ សោធន៍និវត្តន៍ដោយមានពិការភាពមិនប្រែប្រួល។

【 និយមន័យពាក្យ ① 】

គ្រោះថ្នាក់ពេលធ្វើការ

គ្រោះថ្នាក់ពេលធ្វើការ គឺគ្រោះថ្នាក់ដែលអ្នកធ្វើការ រងរបួសឬជំងឺ (របួស ជំងឺ ពិការភាព ស្លាប់ជាដើម) ដោយសារការធ្វើការងារ។

- ការដែលការងារនិងរបួសជាដើមមានហេតុនិងផលទាក់ទងគ្នាមួយហៅថា "ដោយសារការងារ" ។
- ជាទូទៅ និយោជកនិងនាយក ដែលមិនមែនជាអ្នកធ្វើការ មិនអាចទទួលសំណងបានទេ។

◇ របួសដោយសារការងារគឺអ្វី?

ចំពោះថាតើគ្រោះថ្នាក់ណា ដែលគេទទួលស្គាល់ថាជាគ្រោះថ្នាក់ពេលធ្វើការនោះ គេបែងចែកជា3ករណីដូចខាងក្រោម។

<1> ក្នុងករណីធ្វើការងារនៅក្នុងកន្លែងរបស់ក្រុមហ៊ុន

ក្នុងករណីធ្វើការនៅក្នុងចន្លោះកំណត់នៃម៉ោងធ្វើការឬម៉ោងថែមនៅកន្លែង(ការិយាល័យ ឬ រោងចក្រ)របស់ក្រុមហ៊ុន បើគ្មានមូលហេតុពិសេស ត្រូវទទួលស្គាល់ថាជាគ្រោះថ្នាក់ពេលធ្វើការ។

*** ក្នុងករណីខាងក្រោមនេះ គេមិនទទួលស្គាល់ថាជាគ្រោះថ្នាក់ពេលធ្វើការទេ**

① ករណីដែលនៅពេលធ្វើការ អ្នកធ្វើការធ្វើសកម្មភាពឯកជនហើយទទួលគ្រោះថ្នាក់

② ករណីអ្នកធ្វើការ បង្ករគ្រោះថ្នាក់ដោយចេតនា

③ ករណីដែលអ្នកធ្វើការ រងការវាយតប់ពីជនទី៣ ដោយសារកំនុំផ្ទាល់ខ្លួន

<2> ករណីមិនធ្វើការងារនៅក្នុងកន្លែងរបស់ក្រុមហ៊ុន

គ្រោះថ្នាក់ដែលកើតឡើងដោយសារសកម្មភាពឯកជន នៅម៉ោងមិនទាន់ធ្វើការ ដូចជាម៉ោងសំរាកឬម៉ោងមុនឬក្រោយម៉ោងធ្វើការ មិនត្រូវបានទទួលស្គាល់ថាជាគ្រោះថ្នាក់ពេលធ្វើការទេ។ ប៉ុន្តែ បើសិនជាគ្រោះថ្នាក់កើតឡើងដោយសារសម្ភារ: ឧបករណ៍របស់ក្រុមហ៊ុន ឬដោយសារការគ្រប់គ្រងនោះ គឺជាគ្រោះថ្នាក់ពេលធ្វើការ។ ម្យ៉ាងទៀតគ្រោះថ្នាក់ដែលកើតឡើងពេលធ្វើសកម្មភាពសរិ:សាស្ត្រ ដូចជាទៅបន្ទន់។ល។ គឺជាគ្រោះថ្នាក់ពេលធ្វើការ។

<3> ក្នុងករណីធ្វើការងារនៅក្រៅកន្លែងរបស់ក្រុមហ៊ុន

ចំពោះដំណើរជំនួញ ការធ្វើទីផ្សារ បើគ្មានមូលហេតុពិសេស ដូចជាស្វះស្វែងធ្វើសកម្មភាពឯកជន នឹងត្រូវទទួលស្គាល់ជាគ្រោះថ្នាក់ពេលធ្វើការ។

◇ ជំងឺដោយសារការងារគឺអ្វី?

ក្នុងករណីដែលលក្ខខណ្ឌទាំង 3 ខាងក្រោមត្រូវបានបំពេញ ជាទូទៅគេទទួលស្គាល់ថាជា ជំងឺដោយសារការងារ។

<1> នៅកន្លែងធ្វើការមានកត្តាបង្កគ្រោះថ្នាក់

កត្តារូបសាស្ត្របង្កគ្រោះថ្នាក់ សារធាតុគីមី ការងារដែលផ្តល់បន្ទុកដល់រាងកាយធ្ងន់ហួស ។ល។ មានបង្កប់នៅក្នុងការងារ។ (ឧទាហរណ៍ ហ្វីប្រូ (អាសបេស) ។ល។

<2> នៅកន្លែងដែលមានកត្តាគ្រោះថ្នាក់ខ្លាំង រហូតអាចបង្កជាបញ្ហាសុខភាព

<3> របៀបនៃការកើតជាជំងឺ គឺស្របតាមលក្ខណៈវេជ្ជសាស្ត្រ

ជំងឺដោយសារការងារ គឺកើតឡើងដោយសារអ្នកធ្វើការប៉ះពាល់ជាមួយកត្តាបង្កគ្រោះថ្នាក់នៅក្នុងការងារ ហើយបង្កជាជំងឺ។ ដូច្នេះត្រូវតែជាជំងឺកើតឡើងក្រោយពីទទួលរងកត្តាបង្កគ្រោះថ្នាក់។ ពេលវេលានៃការកើតជំងឺគឺខុសគ្នាតាមលក្ខណៈ និងលក្ខខណ្ឌនៃការប៉ះពាល់កត្តាបង្កគ្រោះថ្នាក់។

【 និយមន័យពាក្យ ② 】

គ្រោះថ្នាក់ដោយកត្តានៃការងារលើសពីមួយ

គ្រោះថ្នាក់ដោយកត្តានៃការងារលើសពីមួយ គឺជាគ្រោះថ្នាក់ឬជំងឺដែលត្រូវបានចាត់ទុកថាបង្កដោយការងារនៅទីកន្លែងការងារលើសពីមួយដោយអ្នកធ្វើការលើសពីមួយកន្លែង។ គ្រោះថ្នាក់និងជំងឺជាដើមដែលជាគោលដៅ គឺរួមបញ្ចូលជំងឺខួរក្បាលឬបេះដូង និងជំងឺសតិអារម្មណ៍។

◇ អ្នកធ្វើការលើសពីមួយកន្លែង

អ្នកធ្វើការលើសពីមួយកន្លែង គឺជាអ្នកធ្វើការដែលក្នុងពេលទន្ទឹមគ្នាត្រូវបានជួលបម្រើការងារនៅទីកន្លែងការងារលើសពីមួយដែលមិនមានទំនាក់ទំនងតែមួយនៅពេលគ្រោះថ្នាក់ឬជំងឺជាដើមកើតឡើង។

- អ្នកធ្វើការតែមួយកន្លែង: អ្នកធ្វើការដែលត្រូវបានជួលបម្រើការងារនៅកន្លែងការងារតែមួយ

◇ ការទទួលស្គាល់គ្រោះថ្នាក់ដោយកត្តានៃការងារលើសពីមួយ

បន្ទុកការងារ(រយៈពេលការងារ និងភាពតានតឹងជាដើម)ពីកន្លែងការងារលើសពីមួយ ត្រូវបានវាយតម្លៃជាសរុប ហើយត្រូវបានកំណត់ថាវាអាចត្រូវបានទទួលស្គាល់ថាជាគ្រោះថ្នាក់ការងារដែរឬទេ។ សម្រាប់អ្នកធ្វើការលើសពីមួយកន្លែង ក៏មានករណីដែលបន្ទុកការងារត្រូវបានវិនិច្ឆ័យថាមកពីកន្លែងការងារតែមួយប៉ុណ្ណោះហើយត្រូវបានទទួលស្គាល់ថាបង្កដោយការងារនោះ ដែលនឹងត្រូវបានទទួលស្គាល់ថាជាគ្រោះថ្នាក់ការងារដូចករណីធម្មតា។

→P10,11

【 និយមន័យពាក្យ ③ 】

គ្រោះថ្នាក់ពេលធ្វើដំណើរទៅធ្វើការ

គ្រោះថ្នាក់ពេលធ្វើដំណើរទៅមកពីធ្វើការ គឺគ្រោះថ្នាក់កើតឡើងដោយសារ ការធ្វើដំណើរទៅមកពីធ្វើការនៃអ្នកធ្វើការ។

◇ ការធ្វើដំណើរទៅធ្វើការជាអ្វី?

គឺការធ្វើដំណើរ ① ~③ តាមផ្លូវនិងវិធីដែលមានហេតុផលមួយដើម្បីទៅធ្វើការ។

① ការទៅមកចន្លោះកន្លែងស្នាក់នៅនិងកន្លែងធ្វើការ(កន្លែងចាប់ផ្តើម និងបញ្ចប់ការងារ)

② ការធ្វើដំណើរពីកន្លែងធ្វើការ ដែលកំណត់ក្នុងប្រកាសរបស់ក្រសួងសង្គមកិច្ចនិងការងារ ទៅកន្លែងធ្វើការផ្សេងទៀត(ការធ្វើដំណើរពីកន្លែងធ្វើការមួយទៅកន្លែងធ្វើការមួយទៀត)

③ ការធ្វើដំណើរចន្លោះកន្លែងស្នាក់នៅម្នាក់ឯងជិតកន្លែងធ្វើការនិងផ្ទះខ្លួនឯង



◇ ចន្លោះធ្វើដំណើរទៅធ្វើការ

នៅពេលដាកចេញពីផ្លូវធ្វើដំណើរ ឬផ្អាកការធ្វើដំណើរនោះ ក្នុងចន្លោះដាកចេញ ឬផ្អាកដំណើរនិងការធ្វើដំណើរក្រោយពេលនោះ មិនមែនជាការធ្វើដំណើរទៅធ្វើការទេ។ ប៉ុន្តែ ក្នុងករណីទិញរបស់របរប្រើប្រាស់ឬ ការធ្វើសកម្មភាពស្រដៀងគ្នាក្នុងកំរិតតូចបំផុតនោះ ក្រោយត្រឡប់ចូលផ្លូវដើមវិញ ចាត់ទុកជាការធ្វើដំណើរទៅធ្វើការម្តងទៀត។



◇ ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃគឺអ្វី?

ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ ជាទូទៅគឺមានន័យថាប្រាក់កំរៃធ្យម។ (ច្បាប់ស្តង់ដារការងារមាត្រាទី12)

ប្រាក់កំរៃធ្យម ជាទូទៅមានន័យថា ជាទឹកប្រាក់បានមកពីការគណនាដោយយកទឹកប្រាក់ដែលត្រូវបានបើកអោយអ្នកធ្វើការទាំងអស់ មុនថ្ងៃមានមូលហេតុត្រូវគណនា * ក្នុងចន្លោះ3ខែ ចែកនឹងចំនួនថ្ងៃ(រាប់ទាំងថ្ងៃមិនធ្វើការ)ក្នុងចន្លោះនោះ។ ប្រាក់កំរៃដែលត្រូវយកមកគណនា ទោះបីជាមានឈ្មោះអ្វីក៏ដោយ គឺទឹកប្រាក់ដែលត្រូវបង់សំរាប់ថ្លៃពលកម្ម ដោយនិយោជក។

ប៉ុន្តែប្រាក់ដែលត្រូវបានបង់មិនប្រចាំ ដូចជាប្រាក់ឧបត្ថម្ភសំរាប់ការរៀបអាពាហ៍ពិពាហ៍ ឬប្រាក់បំណាច់ឆ្នាំដែលត្រូវបានបង់លើសពី3 ខែម្តងនោះ មិនត្រូវបានរាប់បញ្ចូលសំរាប់ការគណនានោះទេ។

*****

* ជាថ្ងៃដែលគ្រោះថ្នាក់កើតឡើង ធ្វើអោយមានរបួស ឬស្លាប់ ឬជាថ្ងៃដែលគ្រូពេទ្យវិនិច្ឆ័យថាមានជំងឺ ហើយក្នុងករណីដែលថ្ងៃទូទាត់បិទបញ្ជីបើកប្រាក់ខែត្រូវបានកំណត់ នោះគឺថ្ងៃទូទាត់ថ្មីបំផុត។

ជាគោលការណ៍ ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃសម្រាប់អ្នកធ្វើការលើសពីមួយកន្លែង គឺស្មើនឹងចំនួនសរុបនៃប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃពីកន្លែងការងារលើសពីមួយ។

○ ករណីពិសេស

① ក្នុងករណីដែលប្រាក់កំរៃធ្យម មិនអាចយកមកប្រើជា ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ បាននោះ វិធីគណនា ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃពិសេសនឹងត្រូវយកមកប្រើ។

(a) ក្នុងករណីមានការឈប់សម្រាកព្យាបាលរបួសឬជំងឺមិនមានមូលហេតុមកពីការងារ នៅក្នុងចន្លោះពេលដែលយកមកគណនាប្រាក់កំរៃធ្យម

(b) ក្នុងករណីអ្នកជំងឺរលាកសួត ត្រូវបានផ្លាស់ប្តូរអោយទៅធ្វើការងារផ្សេង។ល។

(c) ក្រៅពីនេះ

② ចំពោះប្រាក់ឧបត្ថម្ភ(សំណង)ឈប់សម្រាកជាដើម ក្នុងករណី ដែលការព្យាបាលបានកន្លងផុតទៅ 1ឆ្នាំ6ខែ នឹងមានការអនុវត្តន៍ទឹកប្រាក់តិចបំផុតនិងច្រើនបំផុតសំរាប់អាយុនិមួយៗ។ ចំពោះការផ្តល់ប្រាក់សោធន៍និវត្តន៍ នឹងមានការអនុវត្តន៍ទឹកប្រាក់តិចបំផុតនិងច្រើនបំផុតសំរាប់អាយុនិមួយៗ ចាប់តាំងពីខែដំបូងនៃការផ្តល់ប្រាក់សោធន៍និវត្តន៍។

គំរូនៃការគណនាប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ

(ឧទាហរណ៍ទី 1)
ប្រាក់កំរៃ 20 ម៉ឺនយ៉ែនក្នុង១ខែ (ថ្ងៃទូទាត់គឺរាល់ថ្ងៃចុងក្រោយនៃខែ) ហើយគ្រោះថ្នាក់បានកើតឡើងនៅខែ10។

20 ម៉ឺនយ៉ែន × 3 ខែ ÷ 92 ថ្ងៃ (ខែ7 (31 ថ្ងៃ) + ខែ8 (31 ថ្ងៃ) + ខែ 9 (30 ថ្ងៃ)
≒ 6,522 យ៉ែន

(ឧទាហរណ៍ទី 2)
អ្នកធ្វើការនៅក្រុមហ៊ុនពីរដោយទទួលប្រាក់កំរៃ 20 ម៉ឺនយ៉ែនពីក្រុមហ៊ុនA និង 10 ម៉ឺនយ៉ែនពីក្រុមហ៊ុនB ក្នុង1ខែ ដោយថ្ងៃទូទាត់គឺរាល់ថ្ងៃចុងក្រោយនៃខែទាំងពីរក្រុមហ៊ុន។ គ្រោះថ្នាក់កើតឡើងនៅខែ7។

ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃពីក្រុមហ៊ុនA
(20 ម៉ឺនយ៉ែន) x 3 ខែ ÷ 91 ថ្ងៃ [ខែ4 (30 ថ្ងៃ) + ខែ5 (31 ថ្ងៃ) + ខែ6 (30 ថ្ងៃ)
= 6,593.40 យ៉ែន
ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃពីក្រុមហ៊ុនB
(10 ម៉ឺនយ៉ែន) x 3 ខែ ÷ 91 ថ្ងៃ [ខែ4 (30 ថ្ងៃ) + ខែ5 (31 ថ្ងៃ) + ខែ6 (30 ថ្ងៃ)
= 3,296.70 យ៉ែន
ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃសរុបបញ្ចូលគ្នា
6,593.40 យ៉ែន + 3,296.70 យ៉ែន ≒ 9,891 យ៉ែន

* "ប្រាក់កំរៃ" មិនរាប់បញ្ចូល ប្រាក់កំរៃម្ហងម្ភាលដែលត្រូវបានបង់លើសពី 3 ខែម្តងនោះទេ។ ចំពោះប្រាក់បំណាច់ឆ្នាំ ដែលត្រូវបានបង់លើសពី 3 ខែម្តង នឹងត្រូវរាប់បញ្ចូលសំរាប់គណនា "ប្រាក់គណនាមូលដ្ឋានជាថ្ងៃ" នៃប្រាក់សោធន៍ និវត្តន៍ត្រួសារពិសេស។ល។

◇ ប្រាក់គណនាមូលដ្ឋានជាថ្ងៃ ជាអ្វី?

ប្រាក់គណនាមូលដ្ឋានជាថ្ងៃ ជាទូទៅ ជាប្រាក់កំរៃពិសេសដែលអ្នកធ្វើការទទួលបានពីនិយោជកក្នុងកំឡុងពេល1ឆ្នាំ រាប់ចាប់ពីថ្ងៃដែលគ្រោះថ្នាក់កើតឡើង ដោយសារការធ្វើការ ឬដោយសារការធ្វើដំណើរទៅធ្វើការ ធ្វើអោយមានរបួស ឬស្លាប់ ឬ ថ្ងៃដែលគ្រូពេទ្យវិនិច្ឆ័យថាមានជំងឺ ជាប្រាក់គណនាមូលដ្ឋានជាឆ្នាំ ចែកនឹង 365។

ប្រាក់កំរៃពិសេស ជាប្រាក់កំរៃដូចជាប្រាក់បំណាច់ឆ្នាំ ដែលត្រូវបានបង់លើសពី 3 ខែម្តង ហើយមិនត្រូវបានរាប់ចូលសំរាប់គណនាប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ។ (មិនរាប់ចូលប្រាក់កំរៃ ដូចជាប្រាក់ឧបត្ថម្ភសំរាប់ការរៀបអាពាហ៍ពិពាហ៍។ល។)

ប៉ុន្តែ ក្នុងករណីដែល ប្រាក់កំរៃពិសេសសរុប លើសពី 20% នៃ ប្រាក់ឧបត្ថម្ភមូលដ្ឋានជាឆ្នាំ (ស្មើនឹង ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ 365 ថ្ងៃ) នោះទឹកប្រាក់ 20%នៃ ប្រាក់ឧបត្ថម្ភមូលដ្ឋានជាឆ្នាំ នឹងក្លាយជា គណនាមូលដ្ឋានជាឆ្នាំ។ (ចំនួនច្រើនបំផុតគឺ 150 ម៉ឺនយ៉ែន)

ជាគោលការណ៍ ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃសម្រាប់អ្នកធ្វើការលើសពីមួយកន្លែងគឺស្មើនឹងចំនួនសរុបនៃប្រាក់ឧបត្ថម្ភមូលដ្ឋានជាឆ្នាំពីកន្លែងការងារលើសពីមួយ ចែកនឹង 365។

【 លក្ខខណ្ឌទទួលស្គាល់តាមប្រភេទជំងឺ ① 】

ជំងឺខួរក្បាល បេះដូង

ចំពោះ "ជំងឺសរសៃឈាមខួរក្បាល" ដូចជាជំងឺងាប់ជាលិកាខួរក្បាល "ជំងឺស្ទះសរសៃឈាមបេះដូង" ដូចជាគាំងបេះដូង បំរែបំរួលដោយសារជំងឺនៃសរសៃឈាមជាដើមដែលជាមូលដ្ឋាននៃការចេញរោគសញ្ញានេះ នឹងចេញរោគសញ្ញាកាន់តែអាក្រក់បន្តិចម្តងៗដោយសារកត្តាពីខាងក្នុងរបស់បុគ្គលដូចជា កត្តានានាដោយសារការរស់នៅប្រចាំថ្ងៃដែលជាចម្បងមានដូចជា អាយុកើនឡើង ទម្លាប់នៃការរស់នៅ បរិស្ថានរស់នៅជាដើម ឬកត្តាហ្សែនជាដើម ប៉ុន្តែក៏មានករណីដែលចេញរោគសញ្ញាដោយសារការងារជាមូលហេតុចម្បងដែរ។ ជំងឺខួរក្បាលឬបេះដូង "ដែលបណ្តាលយ៉ាងច្បាស់មកពីបន្ទកធ្ងន់ហួសកំរិតនៃការងារ " ជាកម្មវត្ថអាចទទួលប្រាក់សំណងបាន។

<ជំងឺជាកម្មវត្ថ>

○ ជំងឺសរសៃឈាមខួរក្បាល

- ជំងឺចេញឈាមក្នុងខួរក្បាល(ឈាមក្នុងខួរក្បាល)
- ជំងឺងាប់ជាលិកាខួរក្បាល
- ជំងឺហូរឈាមក្នុងស្រោមខួរក្បាល
- រោគខួរក្បាលបណ្តាលមកពីលើសឈាម

○ ជំងឺស្ទះសរសៃឈាមបេះដូង

- ជំងឺងាប់ជាលិកាបេះដូង
- ជំងឺខ្ទះឈាមទៅចិញ្ចឹមបេះដូង
- ជំងឺខ្សោយបេះដូងធ្ងន់ធ្ងរ
- ជំងឺគាំងបេះដូង(រួមទាំងការស្លាប់បន្ទាន់ដោយសារបេះដូង)
- ជំងឺអាកទែអាអកបែកញ្ចែក

[លក្ខខណ្ឌទទួលស្គាល់ជាគ្រោះថ្នាក់ការងារ]

ករណីណាមួយក្នុងចំណោមខាងក្រោម ត្រូវបានទទួលស្គាល់ជាគ្រោះថ្នាក់ការងារ។

1. ការងារធ្ងន់ហួសកំរិតក្នុងរយៈពេលវែង

មុនពេលកើតជំងឺ បានធ្វើការធ្ងន់ហួសកំរិតក្នុងរយៈពេលវែង ដែលធ្វើអោយការនឿយហត់ការឡើង។

ក្នុងករណី ① ធ្វើការថែមម៉ោងប្រហែលលើសពី100ម៉ោងក្នុងពេល1ខែមុនចេញរោគសញ្ញា ②រយៈពេលធ្វើការថែមម៉ោងជាមធ្យមប្រចាំខែក្នុងពេល2-6ខែមុនចេញរោគសញ្ញាគឺប្រហែលលើសពី80ម៉ោង ឬ ③ មឹនដល់កម្រិតដូចក្នុង①②ខាងលើទេប៉ុន្តែ បានធ្វើការថែមម៉ោងក្បែរកម្រិតនេះហើយរួមផ្សំនឹងកត្តាណាមួយក្នុងចំណោមកត្តាផ្តល់បន្ទកក្រៅពីម៉ោងពេលធ្វើការក្នុងកម្រិតមួយ (*) ត្រូវបានទទួលស្គាល់នោះវាយតម្លៃថាការងារនិងការចេញរោគសញ្ញាគឺមានទំនាក់ទំនងគ្នាខ្លាំង។

2. ការងារធ្ងន់ហួសកំរិតក្នុងរយៈពេលខ្លី

បានធ្វើការធ្ងន់ហួសកំរិតថ្មីៗមុនកើតជំងឺ

(1) ក្នុងករណីបានធ្វើការធ្ងន់ហួសកំរិត ក្នុងចន្លោះពេលមុនកើតជំងឺដល់មួយថ្ងៃមុន (2) ទោះក្នុងករណីក្នុងចន្លោះពេលមុនកើតជំងឺដល់មួយថ្ងៃមុន មឹនត្រូវបានទទួលស្គាល់ថាបានធ្វើការធ្ងន់ហួសកំរិត ក្នុងករណីបានធ្វើការធ្ងន់ហួសកំរិតជាប់ៗគ្នា ក្នុងកំឡុងពេល1សប្តាហ៍មុននោះ គេគិតថា ការងារនិងការកើតជំងឺគឺមានទំនាក់ទំនងគ្នា។

គួរបញ្ជាក់ថា ករណីមិនអាចវិនិច្ឆ័យថាមានឬគ្មានបន្ទកហួសកម្រិតដោយប្រើតែរយៈពេលធ្វើការ ត្រូវវិនិច្ឆ័យដោយគិតសរុបរួមនូវកត្តាផ្តល់បន្ទក(*) នៃម៉ោងពេលធ្វើការនិងក្រៅម៉ោងពេលធ្វើការ។

3. ព្រឹត្តិការណ៍មិនធម្មតា

បានជួបព្រឹត្តិការណ៍មិនធម្មតាដែលអាចបញ្ជាក់ច្បាស់ស្ថានភាពកើតឡើងដោយពេលវេលានិងទីកន្លែងនៅក្នុងចន្លោះពេលមុនចេញរោគសញ្ញាដល់មួយថ្ងៃមុន

អាចមានដូចជាករណី ស្ថានភាពដែលបង្កឲ្យមានបន្ទកផ្លូវចិត្តខ្លាំងដូចជា ព្រួយបារម្ភ រំភើប ខ្លាច ភ្ជាក់ផ្អើលកម្រិតខ្លាំង ស្ថានភាពដែលបង្កឲ្យមានបន្ទកផ្លូវកាយភ្លាមៗគួរឲ្យកត់សំគាល់ ករណីបានជួបនឹងការប្រែប្រួលបរិស្ថានការងារភ្លាមៗខ្លាំង។

* ពិចារណាថាជាកត្តាផ្តល់បន្ទកដោយសារការងារនូវ ភាពមិនទៀងទាត់នៃពេលម៉ោងការងារ(ការងារពេលម៉ោងធ្វើការវែង ការងារបន្តជាប់គ្មានថ្ងៃសម្រាក ការងារដែលចន្លោះពេលការងារខ្លី ការងារមិនទៀងទាត់/ការងារប្តូរវេន/ការងារយប់ជ្រៅ) ការងារដែលមានការធ្វើដំណើរនៅក្រៅពីកន្លែងធ្វើការ (ការងារចុះបេសកម្មច្រើន ក្រៅពីនេះការងារដែលមានការធ្វើដំណើរនៅក្រៅពីកន្លែងធ្វើការ) ការងារដែលផ្តល់បន្ទកផ្លូវចិត្ត ការងារដែលផ្តល់បន្ទកផ្លូវកាយ បរិស្ថានការងារ(បរិស្ថានសីតុណ្ហភាព សំឡេងរំខាន)

【 លក្ខខណ្ឌទទួលស្គាល់តាមប្រភេទជំងឺ ② 】

ជំងឺសតិអារម្មណ៍

គេគិតថាជំងឺសតិអារម្មណ៍កើតឡើងដោយទំនាក់ទំនងរវាងទំហំបន្ទុកផ្លូវចិត្តពីខាងក្រៅ(ស្ត្រេស) និងសមត្ថភាពទ្រទ្រង់របស់មនុស្សម្នាក់ៗ។
ក្នុងករណីដែលជំងឺសតិអារម្មណ៍កើតឡើងដោយបន្ទុកផ្លូវចិត្ត ដោយសារការងារ នោះជាកម្មវត្ថុនៃសំណងគ្រោះថ្នាក់ការងារ។

[លក្ខខណ្ឌទទួលស្គាល់ជាគ្រោះថ្នាក់ការងារ]

ក្នុងករណីលក្ខខណ្ឌទាំងអស់ខាងក្រោមត្រូវបានបំពេញ នឹងត្រូវបានទទួលស្គាល់ជាគ្រោះថ្នាក់ការងារ។

1. កើតជំងឺសតិអារម្មណ៍ ក្នុងកំរិតទទួលស្គាល់កំណត់មួយ

ជាជំងឺសតិអារម្មណ៍ ដែលមានចែងក្នុងបំណែងចែកជំងឺអន្តរជាតិកំណែទី10(ICD-10) ជំពូកទីV "ជំងឺសតិអារម្មណ៍និងសកម្មភាព"។ (មិនរាប់បញ្ចូលជំងឺរវៃងនិងរបួសក្បាលផ្នែកខាងក្រៅទេ)
(ឧទាហរណ៍) ជំងឺមិនស្រួលអារម្មណ៍ ជំងឺស្ត្រេសបន្ទាន់

2. ត្រូវបានទទួលស្គាល់ថា មានបន្ទុកផ្លូវចិត្តដោយសារការងារខ្លាំង ក្នុងកំឡុង6ខែមុនកើតជំងឺសតិអារម្មណ៍ដែលត្រូវទទួលស្គាល់

(ឧទាហរណ៍)
- ករណីធ្លាប់ជួបគ្រោះថ្នាក់ដល់កម្រិតដែលមានអារម្មណ៍ថាខ្លួននឹងស្លាប់
- ករណីទទួលរងការវាយប្រហារសតិអារម្មណ៍ដែលគ្មានភាពចាំបាច់ក្នុងការងារយ៉ាងច្បាស់ដូចជា ការបដិសេធបុគ្គលិកលក្ខណៈ:ឬភាពជាមនុស្សពីសំណាក់ថ្នាក់លើម្តងហើយម្តងទៀត
- ករណីធ្វើការរយ:ពេលយូរ ។ល។

* ចំពោះករណីដែលព្រឹត្តិការណ៍ដូចជា ការធ្វើបាប ការរំខានកើតឡើងម្តងហើយម្តងទៀត បើសិនជាចាប់ផ្តើមមុនកើតជាជំងឺ 6 ខែ ហើយបន្តរហូតនោះ គេនឹងធ្វើការវាយតំលៃទំហំបន្ទុកផ្លូវចិត្ត នៅចំណុចចាប់ផ្តើមកើតឡើង។

3. មិនត្រូវបានទទួលស្គាល់ថា មានជំងឺសតិអារម្មណ៍ដោយបន្ទុកផ្លូវចិត្តរឿងឯកជន ក្រៅពីការងារ

គេនឹងធ្វើការវិនិច្ឆ័យយ៉ាងជិតដល់ថាតើព្រឹត្តិការណ៍ជាលក្ខណៈបុគ្គលផ្ទាល់ខ្លួន (ការលែងលះ រស់នៅបែកគ្នាជាមួយប្តីប្រពន្ធ ការស្លាប់របស់ប្តីប្រពន្ធ កូន ឪពុកម្តាយ បងប្អូនជាដើម) អាចនិយាយបានថាមិនមែនជាមូលហេតុបង្កជំងឺឬទេ។
គេនឹងពិនិត្យថាតើមានកត្តាផ្ទាល់ខ្លួនដូចជាធ្លាប់មានជំងឺសតិអារម្មណ៍ឬមានជំងឺញឿនគ្រឿងស្រវឹងជាដើមឬទេនិងខ្លឹមសាររបស់វា ហើយករណីមានកត្តាផ្ទាល់ខ្លួននេះ គេនឹងវិនិច្ឆ័យយ៉ាងជិតដល់ថាតើអាចនិយាយបានថាវាជាមូលហេតុបង្កជំងឺឬទេ។

【 លក្ខខណ្ឌទទួលស្គាល់តាមប្រភេទជំងឺ ③ 】

ភាពមិនប្រក្រតីនៃអវ:យ:ខាងលើ

នៅពេលប្រើដើមដៃ ឬប្រអប់ដៃជ្រើនហួសពេក នៅពេលខ្លះមានការលាក ពីក មកស្ពា ដើមដៃ ប្រអប់ដៃ ម្រាមដៃ ឬ ភាពមិនប្រក្រតី នៅសន្លាក់ សរសៃពួរ។ល។
ភាពមិនប្រក្រតីនៃអវ:យ:ខាងលើ គឺសភាពរលាក ឬភាពមិនប្រក្រតីលើរបស់ទាំងអស់នោះ។
<ជោគវិនិច្ឆ័យសំខាន់ៗ>
• Epicondylitis ចំហៀង (medial epicondylitis) • រលាកសរសៃពួរ • ជោគសញ្ញា Cheirospasm
• ជោគសញ្ញាផ្ទួរ្ទូងក្រោមដី Cubital • ការរលាកនៃសរសៃពួរ • ជោគសញ្ញា Cervicobrachial
• ជោគសញ្ញា Supinator (pronator teres) • ជោគសរសៃប្រអប់ដៃ
• ជំងឺរលាកសន្លាក់នៃដៃ • Cheirospasm

[លក្ខខណ្ឌទទួលស្គាល់ជាគ្រោះថ្នាក់ការងារ]

ក្នុងករណីលក្ខខណ្ឌទាំងអស់ខាងក្រោមត្រូវបានបំពេញ នឹងត្រូវបានទទួលស្គាល់ជាគ្រោះថ្នាក់ការងារ។

1. បន្ទាប់ពីធ្វើការដែលមានបន្ទុកខ្លាំងដល់អវ:យវ:ខាងលើ * ។ល។ ក្នុងកំឡុងពេលមួយ(ជាទូទៅលើសពី6ខែ)

សំខាន់មានដូចជាប្រភេទការងារខាងក្រោម។
① ការងារត្រូវធ្វើចលនាអវ:យវ:ខាងលើទៅមកៗជ្រើន
② ការងារធ្វើក្នុងសភាពលើកអវ:យវ:ខាងលើ
③ ការងារដែលធ្វើចលនាកនិងស្ពាតិច ហើយទម្រង់ខ្លួនមិនប្រែប្រួល
④ ធ្វើការងារដែលដាក់បន្ទុកទៅលើតំបន់កំណត់មួយនៃអវ:យវ:ខាងលើ
* អវ:យវ:ខាងលើមាន ផ្នែកខាងក្រោយនៃក្បាល ក ស្ពា ដើមដៃ កំភួនដៃ កដៃ ម្រាមដៃ។

2. បានធ្វើការជួនហួសកំរិតមុនកើតជំងឺ

ក្នុងកំឡុងពេល 3 ខែមុនកើតជំងឺ បានធ្វើការដែលមានបន្ទុកខ្លាំងដល់អវ:យវ:ខាងលើ ក្នុងស្ថានភាពដូចខាងក្រោម។
• ក្នុងករណីដែលបរិមាណការងារស្ទើរតែមិនប្រែប្រួល
  បានធ្វើការជ្រើនជាង អ្នកធ្វើការស្រដៀងគ្នា ដែលមានភេទដូចគ្នា និងអាយុប្រហែលគ្នាលើសពី10%រយ:ពេល3ខែ
• ក្នុងករណីដែលបរិមាណការងារមានការប្រែប្រួល
  ① ថ្ងៃដែលបរិមាណការងារក្នុង1ថ្ងៃលើសថ្ងៃធម្មតា លើសពី20% មាន10ថ្ងៃក្នុង1ខែ ហើយបន្តរយ:ពេល 3 ខែ (ទោះបីបរិមាណការងារទាំងមូលក្នុង1ខែដូចប្រក្រតីក៏ដោយ)
  ② ថ្ងៃដែលបរិមាណការងារក្នុងកំឡុងពេល1ភាគ3នៃការងារ1ថ្ងៃ លើសធម្មតាលើសពី20% មាន10ថ្ងៃក្នុង1ខែ ហើយបន្តរយ:ពេល 3 ខែ (ទោះការងារមធ្យមក្នុង 1ថ្ងៃដូចប្រក្រតីក៏ដោយ)

* ពេលវិនិច្ឆ័យថាបានធ្វើការហួសកំរិតឬអត់ ក្រៅពីបរិមាណការងារ ស្ថានភាពខាងក្រោមក៏ត្រូវបានយកមកពិចារណាដែរ។
• ការងាររយ:ពេលវែង ការងារបន្តជាប់ • មានការបារម្ភខ្លាំង • ការងារទទួលបញ្ហាពីអ្នកដទៃហើយមានចង្វាក់ញាប់ខ្លាំង
• បរិស្ថានការងារមិនសមស្រប • ត្រូវការបញ្ចេញកំលាំងខ្លាំងហួសកំរិត

3. ត្រូវបានទទួលស្គាល់បែបវេជ្ជសាស្ត្រ ថាការងារជួនហួសកំរិត និងការកើតជាជំងឺមានទំនាក់ទំនងគ្នា

【 លក្ខខណ្ឌទទួលស្គាល់តាមប្រភេទជំងឺ ④ 】

ជំងឺឈឺចង្កេះ

ជំងឺឈឺចង្កេះដែលអាចទទួលសំណងគ្រោះថ្នាក់ការងារ មាន2ប្រភេទដូចខាងក្រោម ដែលត្រូវធ្វើការព្យាបាល ហើយប្រភេទនិមួយៗមាន លក្ខខណ្ឌទទួលស្គាល់គ្រោះថ្នាក់ការងារ។

[លក្ខខណ្ឌទទួលស្គាល់ជាគ្រោះថ្នាក់ការងារ]

1. ជំងឺឈឺចង្កេះដែលមានមូលហេតុលក្ខណៈគ្រោះថ្នាក់

ជាការឈឺចង្កេះដោយសាររបួស។ល។ ហើយបំពេញលក្ខខណ្ឌ ① និង ②ខាងក្រោម

① អាចបញ្ជាក់បានយ៉ាងច្បាស់ថា របួសចង្កេះ ឬបានរងកំលាំងខ្លាំងដែលជាមូលហេតុនាំអោយមានរបួសចង្កេះ គឺដោយសារព្រឹត្តិការណ៍ដែលនឲ្យដែលកើតឡើងនៅពេលកំពុងធ្វើការ។

② អាចបញ្ជាក់តាមបែបជីវសាស្ត្រថា កំលាំងដែលធ្វើអំពើលើចង្កេះ បានធ្វើអោយកើតជំងឺឈឺចង្កេះ ឬធ្វើអោយអ្នកដែលមានប្រវត្តិកើតជំងឺឈឺចង្កេះ រើឡើងវិញ។

2. ជំងឺឈឺចង្កេះដែលគ្មានមូលហេតុលក្ខណៈគ្រោះថ្នាក់

ជំងឺឈឺចង្កេះដែលគ្មានមូលហេតុលក្ខណៈគ្រោះថ្នាក់ ត្រូវបានគេបែងចែកសំរាប់រិនិច្ឆយជា2ប្រភេទដូចខាងក្រោម។

◇ ជំងឺឈឺចង្កេះដែលកើតឡើងដោយសារភាពហត់នឿយនៃសាច់ដុំ។ល។

ជំងឺឈឺចង្កេះដែលមានមូលហេតុមកពីភាពនឿយហត់នៃសាច់ដុំ។ល។ ដោយសារធ្វើការងារដូចខាងក្រោមក្នុងរយៈពេលខ្លី(ប្រហែលលើសពី 3 ខែ) អាចទទួលបានសំណងគ្រោះថ្នាក់ការងារ។

- ការងារដែលត្រូវលើករបស់ដែលមានទំងន់លើសពី20kg ឬការងារដែលត្រូវលើករបស់ទំងន់ផ្សេងៗគ្នាក្នុងស្ថានភាពអោន
- ការងារដែលត្រូវរក្សាទម្រង់ខ្លួន ដែលមិនធម្មជាតិខ្លាំងចំពោះចង្កេះ រយៈពេលរាប់ម៉ោងរៀងរាល់ថ្ងៃ
- ការងារដែលត្រូវរក្សាទម្រង់ខ្លួននៅទ្រឹង ហើយមិនអាចដើរបណ្តក្នុងរយៈពេលវែង
- ការងារដែលត្រូវបន្តធ្វើការងារដែលធ្វើអោយចង្កេះមានរញ្ជ័រខ្លាំង

◇ ជំងឺឈឺចង្កេះដែលបណ្តាលមកពីការប្រែប្រួលនៃឆ្នឹង

ជំងឺឈឺចង្កេះដែលមានមូលហេតុមកពីការប្រែប្រួលនៃឆ្នឹង ដោយសារធ្វើការងារជាមួយរបស់ធ្ងន់ដូចខាងក្រោមក្នុងរយៈពេលវែង (ប្រហែលលើសពី 10ឆ្នាំ) អាចទទួលបានសំណងគ្រោះថ្នាក់ការងារបាន។

- ការងារដែលត្រូវលើករបស់ទំងន់លើសពី 30kg ក្នុងកំឡុងពេលលើសពី 1ភាគ3 នៃម៉ោងធ្វើការ
- ការងារដែលត្រូវលើករបស់ទំងន់លើសពី 20kg ក្នុងកំឡុងពេលលើសពី ពាក់កណ្តាលនៃម៉ោងធ្វើការ

* ជំងឺឈឺចង្កេះដែលបណ្តាលមកពីការប្រែប្រួលនៃឆ្នឹង អាចទទួលបានសំណងគ្រោះថ្នាក់ការងារលុះត្រាតែការប្រែប្រួលនោះ "លើសពីកំរិត នៃការប្រែប្រួលឆ្នឹងដោយសារអាយុខ្លាំង"។

ប្រាក់ឧបត្ថម្ភ(សំណង)ព្យាបាលជាដើម

នៅពេលដែលអ្នកធ្វើការមានរបួសឬជំងឺ ដោយសារការធ្វើការឬធ្វើដំណើរទៅមកពីធ្វើការ ហើយត្រូវការព្យាបាល នោះអាចទទួលបាន ការឧបត្ថម្ភសំណងព្យាបាល (ក្នុងករណីគ្រោះថ្នាក់ពេលធ្វើការ) ការឧបត្ថម្ភព្យាបាលសម្រាប់អ្នកធ្វើការលើសពីមួយកន្លែង(សម្រាប់គ្រោះថ្នាក់ដោយកត្តានៃការងារលើសពីមួយ) ឬការឧបត្ថម្ភព្យាបាល (ក្នុងករណីគ្រោះថ្នាក់ពេលធ្វើដំណើរទៅធ្វើការ) រហូតដល់ជំងឺ "នៅនឹង"*។

ខ្លឹមសារនៃការឧបត្ថម្ភ

ប្រាក់ឧបត្ថម្ភ(សំណង)ព្យាបាលជាដើម មាន "ការឧបត្ថម្ភសម្រាប់ការព្យាបាល" និង "ប្រាក់ឧបត្ថម្ភចំណាយសំរាប់ការព្យាបាល"។

- "ការឧបត្ថម្ភសម្រាប់ការព្យាបាល" ជាការឧបត្ថម្ភដោយរបស់ផ្ទាល់ ដោយទទួលការព្យាបាល ឬផ្ទាំ នៅ មន្ទីរពេទ្យគ្រោះថ្នាក់ការងារ ឬស្ថាប័នវេជ្ជសាស្ត្រកំណត់(ខាងក្រោមហៅថា "ស្ថាប័នវេជ្ជសាស្ត្រកំណត់។ល។")។
- "ប្រាក់ឧបត្ថម្ភចំណាយសំរាប់ការព្យាបាល" គឺក្នុងករណីដែលមានមូលហេតុថាគ្មានស្ថាប័នវេជ្ជសាស្ត្រកំណត់នៅជិត ហើយត្រូវទៅទទួលការព្យាបាលនៅស្ថាប័នវេជ្ជសាស្ត្រឬនៅឱសថស្ថាន។ល។ក្រៅពីកន្លែងកំណត់ជាដើម គឺប្រាក់ឧបត្ថម្ភតាមចំនួនប្រាក់ដែលបានបង់ដើម្បីទទួលការព្យាបាល។

ព្រំដែននិងកំឡុងពេលដែលជាកម្មវត្ថុនៃការឧបត្ថម្ភគឺដូចគ្នា។ នៅក្នុងប្រាក់ឧបត្ថម្ភ(សំណង)ព្យាបាលជាដើម រាប់បញ្ចូលទាំងចំណាយផ្សេងៗដូចការព្យាបាលធម្មតាដែរ មានដូចជាថ្លៃព្យាបាល ថ្លៃដេកពេទ្យ ថ្លៃដឹកជញ្ជូន។ល។ ហើយនឹងត្រូវបានផ្តល់អោយរហូតដល់ជំងឺបាននៅនឹង(អាការរោគលែងប្រែប្រួល)។

◇ "នៅនឹង" មានន័យយ៉ាងណា?

មិនមែនមានន័យតែថាគ្រប់សរីរាង្គឬជាលិកាទាំងអស់នៃខ្លួនប្រាណបានត្រលប់ទៅរកសភាពដើមនោះទេ បើសិនជារបួសឬជំងឺមានស្ថេរភាព ហើយស្ថិតក្នុងស្ថានភាពដែលមិនអាចសង្ឃឹមលើប្រសិទ្ធិភាពនៃការព្យាបាល តាមវិធីព្យាបាលទូទៅទទួលស្គាល់ដោយវេជ្ជសាស្ត្រ(*1) បានតទៅទៀត (*2) គឺ(ស្ថានភាពដែល "អាការរោគលែងប្រែប្រួល")។

ហេតុដូច្នេះ "ក្នុងករណីដែលការព្យាបាលដោយ ការដាក់ផ្ទាំ ឬដោយហាត់ប្រាណ។ល។ អាចធ្វើអោយអាការរោគប្រែប្រួលតែមួយរយៈពេលខ្លី" ទោះបីនៅមានរោគសញ្ញាក៏ដោយ ក៏នឹងត្រូវបានវិនិច្ឆ័យថា មិនអាចសង្ឃឹមលើប្រសិទ្ធិភាពនៃការព្យាបាលបាន ហើយចំពោះធានារ៉ាប់រងគ្រោះថ្នាក់ការងារ គេវិនិច្ឆ័យថា "ជំងឺនៅនឹង" (អាការរោគលែងប្រែប្រួល) ហើយមិនផ្តល់ប្រាក់ឧបត្ថម្ភ(សំណង)ព្យាបាលជាដើមទេ។

(*1) "វិធីព្យាបាលទូទៅទទួលស្គាល់ដោយវេជ្ជសាស្ត្រ" គឺព្រំដែននៃការព្យាបាលដែលគេទទួលស្គាល់សំរាប់គ្រោះថ្នាក់ការងារ (ស្របគ្នាជាមួយធានារ៉ាប់រងសុខភាព)។ ហេតុដូច្នេះ វិធីព្យាបាលដែលស្ថិតក្នុងដំណាក់កាលពិសោធន៍ ឬស្រាវជ្រាវ មិនមាននៅក្នុងព្រំដែននៃការព្យាបាលនេះ។

(*2) "ស្ថានភាពដែលមិនអាចសង្ឃឹមលើប្រសិទ្ធិភាពនៃការព្យាបាលបានតទៅទៀត" គឺស្ថានភាពដែលមិនអាចរំពឹងថារបួសឬជំងឺនោះ បានដូចដើមឬប្រសើរឡើងបាន។

នីតិវិធីស្នើរសុំ

● ក្នុងករណីស្នើរសុំការឧបត្ថម្ភព្យាបាល ជាឧបត្ថម្ភសំណងផ្ទៃព្យាបាល និង ឧបត្ថម្ភព្យាបាលសម្រាប់អ្នកដែលធ្វើការលើសពីមួយកន្លែង (ទម្រង់លេខ 5)

តាមរយៈ ស្ថាប័នវេជ្ជសាស្ត្រកំណត់។ល។ដែលបានទទួលការព្យាបាល សូមដាក់ពាក្យស្នើរសុំការឧបត្ថម្ភព្យាបាលសំរាប់ការឧបត្ថម្ភសំណងព្យាបាលនិងការឧបត្ថម្ភព្យាបាលសម្រាប់អ្នកធ្វើការលើសពីមួយកន្លែង (ទម្រង់លេខ 5) ឬពាក្យស្នើរសុំការឧបត្ថម្ភព្យាបាលសំរាប់ការឧបត្ថម្ភព្យាបាល (ទម្រង់ទី3នៃលេខ 16) ទៅប្រធានការិយាល័យស្តង់ដារការងារដែលមានសមត្ថកិច្ច។

● ក្នុងករណីស្នើរសុំការឧបត្ថម្ភចំណាយព្យាបាល ជាឧបត្ថម្ភសំណងផ្ទៃព្យាបាល និង ឧបត្ថម្ភព្យាបាលសម្រាប់អ្នកដែលធ្វើការលើសពីមួយកន្លែង (ទម្រង់លេខ 7)

សូមដាក់ពាក្យស្នើរសុំការឧបត្ថម្ភចំណាយព្យាបាលសំរាប់ការឧបត្ថម្ភសំណងព្យាបាលនិងការឧបត្ថម្ភព្យាបាលសម្រាប់អ្នកធ្វើការលើសពីមួយកន្លែង(ទម្រង់លេខ 7) ឬពាក្យស្នើរសុំការឧបត្ថម្ភចំណាយព្យាបាលសំរាប់ការឧបត្ថម្ភព្យាបាល(ទម្រង់ទី5នៃលេខ 16) ទៅប្រធានការិយាល័យស្តង់ដារការងារដែលមានសមត្ថកិច្ច។

លើសពីនេះ ប្រសិនបើទទួលថ្នាំពីឱសថស្ថាន សូមដាក់ទម្រង់លេខ 7-2 ឬទម្រង់លេខ 16-5-2 ឬប្រសិនបើទទួលការព្យាបាលពីអ្នកព្យាបាលឆ្នឹងយូដូ សូមដាក់ទម្រង់លេខ 7-3 ឬទម្រង់លេខ 16-5-3 ឬប្រសិនបើទទួលការព្យាបាលពីអ្នកចាក់ម្ជុលវិទ្យាសាស្ត្រ អ្នកឯកទេស moxa ឬអ្នកព្យាបាលការម៉ាស្សា shiatsu ដាក់ទម្រង់លេខ 7-4 ឬទម្រង់លេខ 16-5-4 ឬប្រសិនបើទទួលគិលានុបដ្ឋាយិកាតាមផ្ទះពីក្រុមហ៊ុនគិលានុបដ្ឋាយិកាតាមផ្ទះ សូមដាក់ទម្រង់លេខ។ 7-5 ឬទម្រង់លេខ 16-5-5 ។

● ក្នុងករណីប្តូរស្ថាប័នវេជ្ជសាស្ត្រកំណត់។ល។

ក្នុងករណីដែលអ្នកដែលបានទទួល ប្រាក់ឧបត្ថម្ភសម្រាប់ការព្យាបាលនៅស្ថាប័នវេជ្ជសាស្ត្រកំណត់។ល។ រួចហើយ ហើយចង់ប្តូរទៅស្ថាប័នវេជ្ជសាស្ត្រកំណត់។ល។ផ្សេង ដោយមូលហេតុត្រូលប់ទៅស្រុកកំណើត។ល។ តាមរយៈ ស្ថាប័នវេជ្ជសាស្ត្រកំណត់។ល។ផ្លាស់ប្តូររួច សូមដាក់"សេចក្តីជូនដំណឹង (ការផ្លាស់ប្តូរ) មន្ទីរពេទ្យកំណត់សំរាប់ ការឧបត្ថម្ភព្យាបាលសំរាប់ការឧបត្ថម្ភសំណងព្យាបាលនិងការឧបត្ថម្ភព្យាបាលសម្រាប់អ្នកធ្វើការលើសពីមួយកន្លែង"(ទម្រង់លេខ 6) ឬ "សេចក្តីជូនដំណឹងអំពីការផ្លាស់ប្តូរមន្ទីរពេទ្យកំណត់សំរាប់ការឧបត្ថម្ភព្យាបាលសំរាប់ការឧបត្ថម្ភព្យាបាល (ទម្រង់ទី4នៃលេខ16) ទៅប្រធានការិយាល័យស្តង់ដារការងារដែលមានសមត្ថកិច្ច។

* សម្រាប់អ្នកដែលទទួលការព្យាបាលពីស្ថាប័នវេជ្ជសាស្ត្រនិងឱសថស្ថានជាដើមដែលមិនមែនជាស្ថាប័នវេជ្ជសាស្ត្រកំណត់ជាដើម នៅពេលប្តូរទៅស្ថាប័នវេជ្ជសាស្ត្រកំណត់ជាដើម គឺមិនចាំបាច់ដាក់ទម្រង់លេខ 6 ឬ ទម្រង់ទី4នៃលេខ16 ទេ។ សូមដាក់ទម្រង់លេខ 5 និងទម្រង់ទី3នៃលេខ16។

អំពីផ្លែធ្វើដំណើរទៅមកមន្ទីរពេទ្យ

ចំពោះផ្លែធ្វើដំណើរទៅមកមន្ទីរពេទ្យ ជាទូទៅនឹងត្រូវផ្តល់អោយសម្រាប់ការទៅមន្ទីរពេទ្យចំងាយ 2km (*1) ពីកន្លែងស្នាក់នៅឬកន្លែងធ្វើការរបស់អ្នកធ្វើការដែលមានរបួសឬជំងឺ បើសិនបំពេញលក្ខខណ្ឌណាមួយនៃ ① ដល់ ③ ខាងក្រោម។

① បានធ្វើដំណើរទៅមកស្ថាប័នវេជ្ជសាស្ត្រសមស្របនៅក្នុងភូមិ ឃុំ ស្រុកជាមួយគ្នា(*2)។

② នៅពេលដែលគ្មានស្ថាប័នវេជ្ជសាស្ត្រសមស្របនៅក្នុងភូមិ ឃុំ ស្រុកជាមួយគ្នា ហើយបានធ្វើដំណើរទៅមកស្ថាប័នវេជ្ជសាស្ត្រសមស្របនៅក្នុងភូមិ ឃុំ ស្រុកក្បែរគ្នា (រាប់ទាំងពេលដែលមានស្ថាប័នវេជ្ជសាស្ត្រសមស្របនៅក្នុងភូមិ ឃុំ ស្រុកជាមួយគ្នា ប៉ុន្តែស្ថាប័នវេជ្ជសាស្ត្រនៅក្នុងភូមិ ឃុំ ស្រុកក្បែរគ្នាងាយស្រួលទៅជាង)។

③ គ្មានស្ថាប័នវេជ្ជសាស្ត្រសមស្របនៅក្នុងភូមិ ឃុំ ស្រុកជាមួយគ្នា និង នៅក្នុងភូមិ ឃុំ ស្រុកក្បែរគ្នា ហើយបានធ្វើដំណើរទៅមកស្ថាប័នវេជ្ជសាស្ត្រជិតបំផុត ផ្សេងក្រៅពីភូមិ ឃុំ ស្រុកទាំងនេះ។

(*1) ទោះបីចំងាយផ្លូវទៅឬមកជិតជាង2km ក៏មានករណីខ្លះទទួលបានផ្លែធ្វើដំណើរទៅមកមន្ទីរពេទ្យដែរ។

(*2) ស្ថាប័នវេជ្ជសាស្ត្រសមស្រប មានន័យថាជាស្ថាប័នវេជ្ជសាស្ត្រសមស្របសម្រាប់ការព្យាបាលរបួសឬជំងឺ។

ការហួសកាលកំណត់

ដោយសារតែអត្ថប្រយោជន៍នៃការព្យាបាលវេជ្ជសាស្ត្រគឺជាអត្ថប្រយោជន៍ក្នុងប្រភេទ វាមិនមានបញ្ហាជាមួយនឹងលក្ខន្តិក:នៃការកំណត់លើសិទ្ធិទាមទារនោះទេ ប៉ុន្តែប្រសិនបើការទាមទារមិនត្រូវបានធ្វើឡើងក្នុងរយៈពេល 2 ឆ្នាំនៃថ្ងៃបន្ទាប់ នៅថ្ងៃដែលការចំណាយលើការថែទាំត្រូវបានបង់ សិទ្ធិទាមទារនឹង ហួសពេល ដោយសារលក្ខន្តិក:នៃការកំណត់។

ប្រាក់ឧបត្ថម្ភ(សំណង)ឈប់សម្រាកជាដើម

នៅពេលដែលអ្នកធ្វើការមានរបួសឬជំងឺ ដោយសារការធ្វើការឬធ្វើដំណើរទៅមកពីធ្វើការ ហើយត្រូវការព្យាបាលមិនអាចធ្វើការបាន ហើយមិនអាចទទួលកំរៃនោះ ប្រាក់ឧបត្ថម្ភសំណងឈប់សម្រាក (ក្នុងករណី គ្រោះថ្នាក់ពេលធ្វើការ) ឬប្រាក់ឧបត្ថម្ភឈប់សម្រាកសម្រាប់អ្នកធ្វើការលើសពីមួយកន្លែង(ក្នុងករណីគ្រោះថ្នាក់ដោយកត្តានៃការងារលើសពីមួយ) ឬប្រាក់ឧបត្ថម្ភឈប់សម្រាក (ក្នុងករណីគ្រោះថ្នាក់ពេលធ្វើដំណើរទៅធ្វើការ) នឹងត្រូវបានផ្តល់ចាប់ពីថ្ងៃឈប់ទី4ទៅ។

ខ្លឹមសារនៃការឧបត្ថម្ភ

ចាប់ពីឈប់សម្រាកថ្ងៃទី 4 ប្រាក់ឧបត្ថម្ភ(សំណង)ឈប់សម្រាកជាដើម និងប្រាក់ឧបត្ថម្ភឈប់សម្រាកពិសេស នឹងត្រូវបានផ្តល់អោយ ក្នុងករណីដែលលក្ខខណ្ឌទាំង3ខាងក្រោមត្រូវបានបំពេញ។

① ជាការព្យាបាលរបួសឬជំងឺកើតឡើងពីមូលហេតុនៃការធ្វើការឬធ្វើដំណើរទៅមកពីធ្វើការ
② មិនអាចធ្វើការបាន
③ មិនបានទទួលប្រាក់កំរៃ

ក្នុងករណីអ្នកធ្វើការនៅកន្លែងតែមួយ(អ្នកធ្វើការដែលត្រូវបានជួលបម្រើការងារនៅតែមួយកន្លែងធ្វើការ)

- ប្រាក់ឧបត្ថម្ភសំណងឈប់សម្រាក / ប្រាក់ឧបត្ថម្ភឈប់សម្រាក =
  (60% នៃប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ) × ចំនួនថ្ងៃឈប់សម្រាក
- ប្រាក់ឧបត្ថម្ភឈប់សម្រាកពិសេស =
  (20% នៃប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ) × ចំនួនថ្ងៃឈប់សម្រាក

ក្នុងករណីអ្នកធ្វើការលើសពីមួយកន្លែង(អ្នកធ្វើការដែលត្រូវបានជួលបម្រើការងារដោយកន្លែងការងារលើសពីមួយដែលមិនមាននិយោជកតែមួយ)

- ប្រាក់ឧបត្ថម្ភសំណងឈប់សម្រាក / ប្រាក់ឧបត្ថម្ភឈប់សម្រាក =
  (60% នៃប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃដែលស្មើនឹងការបូកសរុបពីកន្លែងធ្វើការលើសពីមួយ) × ចំនួនថ្ងៃឈប់សម្រាក
- ប្រាក់ឧបត្ថម្ភឈប់សម្រាកពិសេស =
  (20% នៃប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃដែលស្មើនឹងការបូកសរុបពីកន្លែងធ្វើការលើសពីមួយ) × ចំនួនថ្ងៃឈប់សម្រាក

3ថ្ងៃដំបូងនៃការឈប់សម្រាក ត្រូវបានហៅថាកំលុងពេលរង់ចាំហើយយោងតាមច្បាប់ស្តង់ដារការងារសម្រាប់គ្រោះថ្នាក់ការងារ នៅកំលុងពេលនេះនិយោជកត្រូវផ្តល់សំណងឈប់សម្រាក (60% នៃប្រាក់កំរៃជាមធ្យមក្នុងមួយថ្ងៃ)។ យ៉ាងណាមិញ ក្នុងករណីគ្រោះថ្នាក់ដោយកត្តានៃការងារលើសពីមួយនិងគ្រោះថ្នាក់ពេលធ្វើដំណើរទៅមកធ្វើការ មិនមានបទប្បញ្ញត្តិតាមច្បាប់ដែលពាក់ព័ន្ធនឹងទំនួលខុសត្រូវសម្រាប់សំណងដោយនិយោជកទេ។
លើសពីនេះ ឧទាហរណ៍ បើអ្នកធ្វើការខកខានការធ្វើការតែមួយផ្នែកនៃម៉ោងធ្វើការដែលមានកំណត់របស់ពួកគេដើម្បីទៅមន្ទីរពេទ្យ ពួកគេអាចទទួលបាន (60% នៃប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ) សម្រាប់ប្រាក់កំរៃនៃពេលវេលាដែលមិនបានធ្វើការនោះ។

នីតិវិធីស្នើរសុំ

សូមដាក់ "ពាក្យស្នើរសុំប្រាក់ឧបត្ថម្ភសំណងឈប់សម្រាក"/ប្រាក់ឧបត្ថម្ភឈប់សម្រាកសម្រាប់អ្នកធ្វើការលើសពីមួយកន្លែង (ទម្រង់លេខ 8)ឬ "ពាក្យស្នើរសុំប្រាក់ឧបត្ថម្ភឈប់សម្រាក" (ទម្រង់ទី6នៃលេខ 16) ទៅប្រធានការិយាល័យស្តង់ដារការងារដែលមានសមត្ថកិច្ច។

ការហួសកាលកំណត់

ចំពោះប្រាក់ឧបត្ថម្ភ(សំណង)ឈប់សម្រាកជាដើម គឺរាល់ថ្ងៃដែលគ្មានកំរៃ ដោយសារការព្យាបាលហើយមិនអាចធ្វើការបាន គឺមានសិទ្ធិស្នើរសុំមកវិញ ក្នុងកំឡុង2ឆ្នាំចាប់ពីថ្ងៃបន្ទាប់បើកន្លងផុតទៅ នឹងហួសកាលកំណត់ លែងមានសិទ្ធិស្នើរសុំតទៅទៀត សូមប្រុងប្រយ័ត្ន។

សោធន៍និវត្តន៍(សំណង)របួសនិងជំងឺជាដើម

នៅពេលដែលអ្នកធ្វើការមានរបួសឬជំងឺ ដោយសារការធ្វើការឬធ្វើដំណើរទៅមកពីធ្វើការ ក្រោយពីថ្ងៃចាប់ផ្តើមព្យាបាលអស់រយៈពេល 1ឆ្នាំ6ខែ បើបំពេញលក្ខខណ្ឌដូចខាងក្រោម អាចទទួលបាន សោធន៍និវត្តន៍សំណងរបួសនិងជំងឺ(ក្នុងករណី គ្រោះថ្នាក់ពេលធ្វើការ) សោធន៍និវត្តន៍របួសនិងជំងឺសម្រាប់អ្នកធ្វើការលើសពីមួយកន្លែង(សម្រាប់គ្រោះថ្នាក់ដោយកត្តានៃការងារលើសពីមួយ) ឬសោធន៍និវត្តន៍របួសនិងជំងឺ (ក្នុងករណីគ្រោះថ្នាក់ពេលធ្វើដំណើរទៅធ្វើការ)។

(1) របួសឬជំងឺមិនបានជា

(2) កំរិតនៃពិការភាពដោយសារ របួសឬជំងឺនោះ ស្ថិតក្នុងកម្រិតស្របតាមកំរិតរបួសនិងជំងឺក្នុងតារាងកំរិតរបួសនិងជំងឺ

ខ្លឹមសារនៃការឧបត្ថម្ភ

សោធន៍និវត្តន៍(សំណង)របួសនិងជំងឺជាដើម ប្រាក់ឧបត្ថម្ភរបួសនិងជំងឺពិសេស សោធន៍និវត្តន៍របួសនិងជំងឺពិសេស នឹងត្រូវបានផ្តល់តាមកំរិតនៃរបួសឬជំងឺ។

កំរិតរបួសឬជំងឺ	សោធន៍និវត្តន៍(សំណង) របួសនិងជំងឺជាដើម	ប្រាក់ឧបត្ថម្ភរបួសនិងជំងឺ ពិសេស(បើកផ្តាច់)	សោធន៍និវត្តន៍របួសនិងជំងឺ ពិសេស
កំរិតទី1	ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ ចំនួន313ថ្ងៃ	114ម៉ឺនយ៉េន	ប្រាក់គណនាមូលដ្ឋានជាថ្ងៃ ចំនួន313ថ្ងៃ
កំរិតទី2	ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ ចំនួន277ថ្ងៃ	107ម៉ឺនយ៉េន	ប្រាក់គណនាមូលដ្ឋានជាថ្ងៃ ចំនួន277ថ្ងៃ
កំរិតទី3	ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ ចំនួន245ថ្ងៃ	100ម៉ឺនយ៉េន	ប្រាក់គណនាមូលដ្ឋានជាថ្ងៃ ចំនួន245ថ្ងៃ

ខែដែលប្រាក់សោធន៍និវត្តន៍ត្រូវបានបង់

សោធន៍និវត្តន៍(សំណង)របួសនិងជំងឺជាដើម ចាប់ផ្តើមផ្តល់អោយសម្រាប់ខែបន្ទាប់ពីខែដែលលក្ខខណ្ឌ(1)និង(2)ខាងលើត្រូវបានបំពេញ ហើយរៀងរាល់ខែ 2 ខែ4 ខែ6 ខែ8 ខែ10 ខែ12 ត្រូវជា6ដង ដែលរាល់ដង ប្រាក់សម្រាប់ 2ខែ នឹងត្រូវបានបើកអោយ។

* អ្នកដែលមានរបួសជំងឺកំរិតទី1 ឬពិការភាពនៃសរីរាង្គក្នុងទ្រូងឬពោះ ផ្លូវចិត្តសរសៃប្រសាទនៃកំរិតទី2 ហើយជាក់ស្តែងត្រូវការការថែទាំនោះ អាចទទួលប្រាក់ឧបត្ថម្ភ(សំណង)សម្រាប់ការថែទាំជាដើមបាន។ (→ P33)

នីតិវិធីស្នើរសុំ

ការសម្រេចថាផ្តល់ឬមិនផ្តល់សោធន៍និវត្តន៍(សំណង)របួសនិងជំងឺជាដើម គឺសិទ្ធិរបស់ប្រធានការិយាល័យស្តង់ដារការងារ ហើយមិនចាំបាច់ស្នើរសុំទេ ប៉ុន្តែ1ឆ្នាំ6ខែបន្ទាប់ពីចាប់ផ្តើមព្យាបាល ហើយជំងឺមិនបានជាទេនោះ ក្នុងកំឡុងពេល1ខែក្រោយមក សូមដាក់ "ការផ្តល់ដំណឹងអំពីស្ថានភាពនៃរបួសនិងជំងឺ។ល។" (ទម្រង់ទី2 នៃលេខ 16) ទៅប្រធានការិយាល័យស្តង់ដារការងារដែលមានសមត្ថកិច្ច។

ប្រាក់ឧបត្ថម្ភ(សំណង)ពិការភាពជាដើម

នៅពេលដែលរបួសឬជំងឺ ដោយសារការធ្វើការឬធ្វើដំណើរទៅមកពីធ្វើការបានសះស្បើយ ហើយមានពិការភាពនៅលស់ទុកលើខ្លួនប្រាណនោះ អាចទទួល ប្រាក់ឧបត្ថម្ភសំណងពិការភាព (ក្នុងករណី គ្រោះថ្នាក់ពេលធ្វើការ) ប្រាក់ឧបត្ថម្ភពិការភាពសម្រាប់អ្នកធ្វើការលើសពីមួយកន្លែង(ក្នុងករណីគ្រោះថ្នាក់ដោយកត្តានៃការងារលើសពីមួយ) ឬ ប្រាក់ឧបត្ថម្ភពិការភាព (ក្នុងករណីគ្រោះថ្នាក់ពេលធ្វើដំណើរទៅធ្វើការ)។

ខ្លឹមសារនៃការឧបត្ថម្ភ

នៅពេលពិការភាពនៅសល់ ស្របតាមកំរិតពិការភាពមាននៅក្នុងតារាងកំរិតពិការភាពនោះ កំរិតពិការភាពនិមួយៗនឹងទទួលបានការផ្តល់ដូចខាងក្រោម។

- នៅពេលស្ថិតក្នុងកំរិតពិការភាពទី1 ដល់ទី 7
  សោធន៍និវត្តន៍(សំណង)ពិការភាពជាដើម ប្រាក់ឧបត្ថម្ភពិការភាពពិសេស សោធន៍និវត្តន៍ពិការភាពពិសេស
- នៅពេលស្ថិតក្នុងកំរិតពិការភាពទី8 ដល់ទី 14
  ប្រាក់បើកផ្តាច់(សំណង)ពិការភាពជាដើម ប្រាក់ឧបត្ថម្ភពិការភាពពិសេស ប្រាក់បើកផ្តាច់ពិការភាពពិសេស

កំរិតពិការភាព	ប្រាក់ឧបត្ថម្ភ(សំណង)ពិការភាពជាដើម		ប្រាក់ឧបត្ថម្ភពិការភាពពិសេស (*)		ប្រាក់សោធន៍និវត្តន៍ពិការភាពពិសេស		ប្រាក់បើកផ្តាច់ពិការភាពពិសេស	
កំរិតទី1	សោធន៍និវត្តន៍	ប្រាក់ឧបត្ថម្ភមួលម្នាងជាថ្ងៃចំនួន 313ថ្ងៃ	ប្រាក់បើកផ្តាច់	3,420,000 យ៉ន	សោធន៍និវត្តន៍	ប្រាក់គណនាមួលម្នាងជាថ្ងៃចំនួន 313ថ្ងៃ		
កំរិតទី2	〃	〃 277ថ្ងៃ	〃	3,200,000 យ៉ន	〃	〃 277ថ្ងៃ		
កំរិតទី3	〃	〃 245ថ្ងៃ	〃	3,000,000 យ៉ន	〃	〃 245ថ្ងៃ		
កំរិតទី4	〃	〃 213ថ្ងៃ	〃	2,640,000 យ៉ន	〃	〃 213ថ្ងៃ		
កំរិតទី5	〃	〃 184 ថ្ងៃ	〃	2,250,000 យ៉ន	〃	〃 184 ថ្ងៃ		
កំរិតទី6	〃	〃 156ថ្ងៃ	〃	1,920,000 យ៉ន	〃	〃 156ថ្ងៃ		
កំរិតទី7	〃	〃 131ថ្ងៃ	〃	1,590,000 យ៉ន	〃	〃 131ថ្ងៃ		
កំរិតទី8	ប្រាក់បើកផ្តាច់	〃 503ថ្ងៃ	〃	650,000 យ៉ន			ប្រាក់បើកផ្តាច់	ប្រាក់គណនាមួលម្នាងជាថ្ងៃចំនួន 503 ថ្ងៃ
កំរិតទី9	〃	〃 391ថ្ងៃ	〃	500,000 យ៉ន			〃	〃 391ថ្ងៃ
កំរិតទី10	〃	〃 302ថ្ងៃ	〃	390,000 យ៉ន			〃	〃 302ថ្ងៃ
កំរិតទី11	〃	〃 223ថ្ងៃ	〃	290,000 យ៉ន			〃	〃 223ថ្ងៃ
កំរិតទី12	〃	〃 156ថ្ងៃ	〃	200,000 យ៉ន			〃	〃 156ថ្ងៃ
កំរិតទី13	〃	〃 101ថ្ងៃ	〃	140,000 យ៉ន			〃	〃 101ថ្ងៃ
កំរិតទី14	〃	〃 56ថ្ងៃ	〃	80,000 យ៉ន			〃	〃 56ថ្ងៃ

* ក្នុងករណីបានទទួល ប្រាក់ឧបត្ថម្ភរបួសនិងជំងឺពិសេស លើជំងឺតែមួយរួចហើយ នឹងត្រូវដកទឹកប្រាក់នោះចេញ។
* អ្នកដែលមានរបួសជំងឺកំរិតទី1 ឬពិការភាពនៃសរីរាង្គក្នុងទ្រូងឬពោះ ផ្លូវចិត្តសរសៃប្រសាទនៃកំរិតទី2 ហើយជាក់ស្តែងត្រូវការការថែទាំនោះ អាចទទួលប្រាក់ឧបត្ថម្ភ(សំណង)សម្រាប់ការថែទាំជាដើមបាន។ (→ P33)

នីតិវិធីស្នើរសុំ

សូមដាក់"ពាក្យស្នើរសុំប្រាក់ឧបត្ថម្ភសំណងពិការភាព / ប្រាក់ឧបត្ថម្ភពិការភាពសម្រាប់អ្នកធ្វើការលើសពីមួយកន្លែង " (ទម្រង់លេខ 10) ឬពាក្យស្នើរសុំប្រាក់ឧបត្ថម្ភពិការភាព (ទម្រង់ទី7នៃលេខ 16) ទៅប្រធានការិយាល័យស្តង់ដារការងារដែលមានសមត្ថកិច្ច។

ការហួសកាលកំណត់

ចំពោះប្រាក់ឧបត្ថម្ភ(សំណង)ពិការភាពជាដើម រាប់ចាប់ពីថ្ងៃបន្ទាប់ពីថ្ងៃដែលជំងឺបានជា បើរយៈពេល 5ឆ្នាំបានកន្លងផុតទៅ នឹងហួសកាលកំណត់ លែងមានសិទ្ធិស្នើរសុំតទៅទៀត សូមប្រុប្រយ័ត្ន។

តារាងកំរិតពិការភាព

ច្បាប់ស្តីអំពីការអនុវត្តន៍នៃជានាវ៉ាប់រងគ្រោះថ្នាក់ការងារលើអ្នកធ្វើការ
តារាងភ្ជាប់ទី1 តារាងកំរិតពិការភាព

កំរិតពិការភាព	ខ្លឹមសារនៃការឧបត្ថម្ភ	ពិការភាពលើខ្លួនប្រាណ
កំរិតទី 1	ផ្តល់ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃចំនួន313ថ្ងៃ សំរាប់ពិការភាព1ឆ្នាំ	1 អ្នកដែលងងឹតភ្នែកទាំងសងខាង 2 អ្នកដែលបាត់បង់មុខងារទំពារនិងភាសា 3 អ្នកដែលមានពិការភាពតួនាទីសរសៃប្រសាទឬសតិអារម្មណ៍ធ្ងន់ធ្ងរ ហើយត្រូវការការថែទាំជាប្រចាំ 4 អ្នកដែលមានពិការភាពនៃតួនាទីសរីរាង្គក្នុងទ្រូងឬពោះធ្ងន់ធ្ងរ ហើយត្រូវការការថែទាំជាប្រចាំ 5. លុបចេញ 6 អ្នកដែលបានបាត់អវ:យវ:ខាងលើទាំងសងខាងចាប់ពីសន្លាក់កែងដៃ 7 អ្នកដែលបានបាត់បង់តួនាទីអវ:យវ:ខាងលើទាំងសងខាងទាំងស្រុង 8 អ្នកដែលបានបាត់បង់តួនាទីអវ:យវ:ខាងក្រោមទាំងសងខាងចាប់ពីសន្លាក់ជង្គង់ 9 អ្នកដែលបានបាត់បង់តួនាទីអវ:យវ:ខាងក្រោមទាំងសងខាងទាំងស្រុង
កំរិតទី 2	ដូចគ្នាចំនួន 277 ថ្ងៃ	1 អ្នកដែលបានងងឹតភ្នែក1 ហើយសមត្ថភាពមើលនៃភ្នែកមួយទៀតនៅសល់ក្រោម 0.02 2 អ្នកដែលមានសមត្ថភាពមើលនៃភ្នែកទាំងពីរនៅសល់ក្រោម0.02 2-2 បន្សល់ទុកពិការភាពលើតួនាទីប្រព័ន្ធប្រសាទឬសតិអារម្មណ៍ធ្ងន់ធ្ងរ ហើយត្រូវការការថែទាំជារឿយៗ 2-3 ពិការភាពនៃតួនាទីសរីរាង្គក្នុងទ្រូងឬពោះធ្ងន់ធ្ងរ ហើយត្រូវការការថែទាំជារឿយៗ 3 អ្នកដែលបានបាត់អវ:យវ:ខាងលើទាំងសងខាងចាប់ពីសន្លាក់កដៃ 4 អ្នកដែលបានបាត់អវ:យវ:ខាងក្រោមទាំងសងខាងចាប់ពីសន្លាក់កជើង
កំរិតទី 3	ដូចគ្នាចំនួន 245 ថ្ងៃ	1 អ្នកដែលបានងងឹតភ្នែក1 ហើយសមត្ថភាពមើលនៃភ្នែកមួយទៀតនៅសល់ក្រោម 0.06 2 អ្នកដែលបាត់បង់មុខងារទំពារនិងភាសា 3 អ្នកដែលមានពិការភាពតួនាទីសរសៃប្រសាទឬសតិអារម្មណ៍ធ្ងន់ធ្ងរ ហើយមិនអាចធ្វើការអស់មួយជីវិត 4 អ្នកដែលមានពិការភាពនៃតួនាទីសរីរាង្គក្នុងទ្រូងឬពោះធ្ងន់ធ្ងរ ហើយមិនអាចធ្វើការអស់មួយជីវិត 5 អ្នកដែលបានបាត់ម្រាមដៃទាំងសងខាងទាំងអស់

កំរិតពិការភាព	ខ្លឹមសារនៃការឧបត្ថម្ភ	ពិការភាពលើខ្លួនប្រាណ
កំរិតទី 4	ដូចគ្នាចំនួន 213 ថ្ងៃ	1 អ្នកដែលមានសមត្ថភាពមើលនៃភ្នែកទាំងពីរនៅសល់ក្រោម 0.06 2 អ្នកដែលបានបន្សល់ទុកពិការភាពមុខងារទំពារនិងភាសាធ្ងន់ធ្ងរ 3 ត្រចៀកទាំងសងខាងថ្លង់ទាំងស្រុង 4 អ្នកដែលបានបាត់អវ:យវ:ខាងលើ1ចាប់ពីសន្លាក់កែងដៃ 5 អ្នកដែលបានបាត់អវ:យវ:ខាងក្រោម1ចាប់ពីសន្លាក់ជង្គង់ 6 អ្នកដែលបានបាត់បង់តួនាទីម្រាមដៃទាំងសងខាងទាំងអស់ 7 អ្នកដែលបានបាត់ប្រអប់ជើងទាំងពីរចាប់ពីសន្លាក់លីសហ្ស្រង់
កំរិតទី 5	ដូចគ្នាចំនួន184 ថ្ងៃ	1 អ្នកដែលបានងងឹតភ្នែក1 ហើយសមត្ថភាពមើលនៃភ្នែកមួយទៀតនៅសល់ក្រោម 0.1 1-2 អ្នកដែលមានពិការភាពតួនាទីសរសៃប្រសាទឬសតិអារម្មណ៍ធ្ងន់ធ្ងរ ហើយអាចធ្វើបានតែការងារស្រាលៗ 1-3 អ្នកដែលមានពិការភាពនៃតួនាទីសរីរាង្គក្នុងទ្រូងឬពោះធ្ងន់ធ្ងរ 2 អ្នកដែលបានបាត់អវ:យវ:ខាងលើ1ចាប់ពីសន្លាក់កដៃ 3 អ្នកដែលបានបាត់អវ:យវ:ខាងក្រោម1ចាប់ពីសន្លាក់កជើង 4 អ្នកដែលបានបាត់បង់តួនាទីអវ:យវ:ខាងលើទាំងស្រុង1 5 អ្នកដែលបានបាត់បង់តួនាទីអវ:យវ:ខាងក្រោមទាំងស្រុង1 6 អ្នកដែលបានបាត់ម្រាមជើងទាំងសងខាងទាំងអស់
កំរិតទី 6	ដូចគ្នាចំនួន156 ថ្ងៃ	1 អ្នកដែលមានសមត្ថភាពមើលនៃភ្នែកទាំងពីរនៅសល់ក្រោម0.1 2 អ្នកដែលបានបន្សល់ទុកពិការភាពមុខងារទំពារនិងភាសាធ្ងន់ធ្ងរ 3 អ្នកដែលត្រចៀកទាំងសងខាងមិនអាចស្តាប់សម្លេងខ្លាំងបានលុះត្រាតែប៉ះ 3-2 អ្នកដែលបានបាត់បង់សមត្ថភាពលើនៃត្រចៀក 1 ត្រចៀកម្ខាងទៀត មិនអាចស្តាប់សំលេងនិយាយធម្មតាបានពេលឃ្លាតចំងាយ 40 សង់ទីម៉ែត្រ

កំរិតពិការភាព	ខ្លឹមសារនៃការឧបត្ថម្ភ	ពិការភាពលើខ្លួនប្រាណ
		4 អ្នកដែលរៀចស្អឹងខ្នងធ្ងន់ធ្ងរ ឬមានសន្សល់ទុកពិការភាពការធ្វើចលនា 5 អ្នកដែលបានបាត់បង់តួនាទីសន្លាក់ជំនៃអវ:យវ:ខាងលើ1 ចំនួន2ក្នុងចំណោម3 6 អ្នកដែលបានបានបាត់បង់តួនាទីសន្លាក់ជំនៃអវ:យវ:ខាងក្រោម1 ចំនួន2ក្នុងចំណោម3 7 អ្នកដែលបានបាត់ម្រាមដៃទាំង5ឬម្រាមដៃ4រួមទាំងមេដៃនៃដៃ1
កំរិតទី7	ដូចគ្នាចំនួន 131 ថ្ងៃ	1 អ្នកដែលបានងងឹតភ្នែក1 ហើយសមត្ថភាពមើលនៃភ្នែកមួយទៀតនៅសល់ក្រោម 0.6 2 អ្នកដែលសមត្ថភាពលីនៃត្រចៀកទាំងពីរ ទៅជាមិនអាចស្តាប់សំលេងនិយាយធម្មតាបានពេលឃ្លាតចំងាយឆ្ងាយជាង 40 សង់ទីម៉ែត្រ 2-2 អ្នកដែលបានបាត់បង់សមត្ថភាពលីនៃត្រចៀក 1 ត្រចៀកម្ខាងទៀត មិនអាចស្តាប់សំលេងនិយាយធម្មតាបានពេលឃ្លាតចំងាយលើស 1 ម៉ែត្រ 3 អ្នកដែលមានពិការភាពតួនាទីសរសៃប្រសាទឬសតិអារម្មណ៍ ហើយអាចធ្វើបានតែការងារស្រាសៗ 4 លុបចោល 5 អ្នកដែលមានពិការភាពនៃតួនាទីសរីរាង្គក្នុងទ្រូងឬពោះ ហើយអាចធ្វើបានតែការងារស្រាសៗ 6 អ្នកដែលបានបាត់ម្រាមដៃ3 រួមទាំងមេដៃ ឬបាត់ម្រាមដៃ 4 រួមទាំងមេដៃនៃដៃ1 7 អ្នកដែលបានបាត់តួនាទីម្រាមដៃទាំង5 ម្រាមដៃ4រួមទាំងមេដៃនៃដៃ1 8 អ្នកដែលបានបាត់ជើង1ចាប់ពីសន្លាក់លីសហ្វ្រង់ 9 អ្នកដែលបានបន្សល់ទុកសន្លាក់ខូចនៅអវ:យវ:ខាងលើ1 ហើយប៉ះពាល់ធ្ងន់ធ្ងរដល់ការធ្វើចលនា 10 អ្នកដែលបានបន្សល់ទុកសន្លាក់ខូចនៅអវ:យវ:ខាក្រោម 1 ហើយប៉ះពាល់ធ្ងន់ធ្ងរដល់ការធ្វើចលនា 11 អ្នកដែលបានបាត់តួនាទីម្រាមជើងទាំងសងខាងទាំងអស់ 12 អ្នកដែលបានបន្សល់ភាពអាក្រក់ធ្ងន់ធ្ងរលើរូបរាងខាងក្រៅ 13 អ្នកដែលបានបាត់ពងស្វាសទាំងសងខាង
កំរិតទី 8	ប្រាក់ឧបត្ថម្ភ មូលដ្ឋានជាថ្ងៃចំនួន 503 ថ្ងៃ	1 អ្នកដែលបានងងឹតភ្នែក1 ហើយសមត្ថភាពមើលនៃភ្នែកមួយទៀតនៅសល់ក្រោម 0.02 2 អ្នកដែលបន្សល់ផលប៉ះពាល់ដល់ការធ្វើចលនានៅស្អឹងខ្នង 3 អ្នកដែលបានបាត់ម្រាមដៃ2 រួមទាំងមេដៃ ឬបាត់ម្រាមដៃ 3 ក្រៅពីមេដៃនៃដៃ1 4 អ្នកដែលបានបាត់តួនាទីម្រាមដៃ3រួមទាំងមេដៃ ឬបាត់តួនាទីម្រាមដៃ4ក្រៅពីមេដៃនៃដៃ1 5 អ្នកដែលអវ:យវ:ខាងក្រោម1 បានរួញលើសពី 5 សង់ទីម៉ែត្រ 6 អ្នកដែលបានបាត់បង់តួនាទីសន្លាក់ជំនៃអវ:យវ:ខាងលើ1នៃចំនួន1ក្នុងចំណោម3 7 អ្នកដែលបានបាត់បង់តួនាទីសន្លាក់ជំនៃអវ:យវ:ខាងក្រោម 1នៃចំនួន1ក្នុងចំណោម3 8 អ្នកដែលបានបន្សល់ទុកសន្លាក់ខូចនៅអវ:យវ:ខាងលើ1 9 អ្នកដែលបានបន្សល់ទុកសន្លាក់ខូចនៅអវ:យវ:ខាងក្រោម1 10 អ្នកដែលជើង1បានបាត់ម្រាមទាំងអស់
កំរិតទី9	ដូចគ្នាចំនួន 391 ថ្ងៃ	1 អ្នកដែលមានសមត្ថភាពមើលនៃភ្នែកទាំងពីរនៅសល់ក្រោម0.6 2 អ្នកដែលមានសមត្ថភាពមើលនៃភ្នែក1នៅសល់ក្រោម 0.6 3 អ្នកដែល ភ្នែកទាំងសងខាងមានភាពងងឹតមួយចំហៀង ដោយមានផ្នែកមើលឃើញតូចជាងមុន 4 អ្នកដែលបន្សល់ទុកការខូចខាតត្របកភ្នែកទាំងពីរធ្ងន់ធ្ងរ 5 អ្នកដែលបន្សល់ទុកការខូចខាតច្រមុះធ្ងន់ធ្ងរ 6 អ្នកដែលបន្សល់ទុកពិការភាពមុខងារទំពារនិងភាសា 6-2 អ្នកដែលសមត្ថភាពលីនៃត្រចៀកទាំងពីរ ទៅជាមិនអាចស្តាប់សំលេងនិយាយធម្មតាបានពេលឃ្លាតចំងាយលើស 1 ម៉ែត្រ 6-3 អ្នកដែលត្រចៀក1មិនអាចស្តាប់សម្លេងខ្លាំងបានលុះត្រាតែប៉ះត្រចៀក ហើយសមត្ថភាពលីនៃត្រចៀក 1 ទៀត មិនអាចស្តាប់សំលេងនិយាយធម្មតាបានពេលឃ្លាតចំងាយលើស 1 ម៉ែត្រ 7 ត្រចៀក1 ស្តាប់លែងលីទាំងស្រុង 7-2 អ្នកដែលមានពិការភាពតួនាទីសរសៃប្រសាទឬសតិអារម្មណ៍ ហើយការងារដែលអាចធ្វើបានត្រូវបានកំរិតខ្លាំង

កំរិតពិការភាព	ខ្លឹមសារនៃការឧបត្ថម្ភ	ពិការភាពលើខ្លួនប្រាណ
		7-3 អ្នកដែលមានពិការភាពនៃតួនាទីសរីរាង្គក្តុងទ្រូងឬពោះ ហើយការងារដែលអាចធ្វើបានត្រូវបានកំរិតខ្លាំង 8 អ្នកដែលមានដៃ1បានបាត់មេដៃ ឬម្រាមដៃ2ក្រៅពីមេដៃ 9 អ្នកដែលបានបាត់ម្រាមដៃ2 រួមទាំងមេដៃ ឬបាត់តួនាទីម្រាមដៃ 3ក្រៅពីមេដៃនៃដៃ1 10 អ្នកដែលមានជើង1បានបាត់ម្រាមជើង2 រួមទាំងម្រាមជើងទី1 11 អ្នកដែលមានជើង1មានម្រាមជើងទាំងអស់បាត់តួនាទី 11-2 អ្នកដែលបានបន្សល់ភាពអាក្រក់ធ្ងន់ធ្ងរលើរូបរាងខាងក្រៅ 12 អ្នកដែលបានបន្សល់ពិការភាពដល់ប្រដាប់បន្តពូជ
កំរិតទី10	ដូចគ្នាចំនួន 302 ថ្ងៃ	1 អ្នកដែលមានសមត្ថភាពមើលនៃភ្នែក1 នៅសល់ក្រោម 0.1 1-2 អ្នកដែលមើលទៅមុខឃើញបែក 2 អ្នកដែលបានបន្សល់ទុកពិការភាពមុខងារទំពារនិងភាសា 3 អ្នកដែលបានទទួលការធ្វើជំនួសធ្មេញច្រើនជាង 14 ដើម 3-2 អ្នកដែលសមត្ថភាពលីនៃត្រចៀកទាំងពីរ ទៅជាមានភាពល់បាកខ្លាំងក្នុងការស្តាប់សំលេងនិយាយធម្មតាបានពេលឃ្លាតចំងាយលើស 1 ម៉ែត្រ 4 អ្នកដែលត្រចៀក1មិនអាចស្តាប់សម្លេងខ្លាំងបានលុះត្រាតែប៉ះត្រចៀក 5 លុបចេញ 6 អ្នកដែលមានដៃ1មានមេដៃ ឬម្រាមដៃ2ក្រៅពីមេដៃ បាត់បង់តួនាទី 7 អ្នកដែលអវ:យវ:ខាងក្រោម1 បានរួញលើសពី 3 សង់ទីម៉ែត្រ 8 អ្នកដែលមានជើង1 បានបាត់ម្រាមជើងទី1 ឬ ម្រាមជើង4ផ្សេងទៀត 9 អ្នកដែលមានពិការភាពធ្ងន់ធ្ងរដល់តួនាទីសន្លាក់ធំនៃអវ:យវ:ខាងលើ1 ចំនួន1ក្នុងចំណោម3 10 អ្នកដែលមានពិការភាពធ្ងន់ធ្ងរដល់តួនាទីសន្លាក់ធំនៃអវ:យវ:ខាងក្រោម1 ចំនួន1ក្នុងចំណោម3

កំរិតពិការភាព	ខ្លឹមសារនៃការឧបត្ថម្ភ	ពិការភាពលើខ្លួនប្រាណ
កំរិតទី 11	ដូចគ្នាចំនួន 233 ថ្ងៃ	1 អ្នកដែលមានការប៉ះពាល់ធ្ងន់ធ្ងរដល់តួនាទីតម្រូវឬប៉ះពាល់ដល់ចលនារបស់ត្រាប់ភ្នែកទាំងសងខាង 2 អ្នកដែលបន្សល់ទុកការប៉ះពាល់ធ្ងន់ធ្ងរដល់ចលនានៃត្របកភ្នែកទាំងពីរ 3 អ្នកដែលបន្សល់ទុកការខូចខាតត្របកភ្នែក1ធ្ងន់ធ្ងរ 3-2អ្នកដែលបានទទួលការធ្វើជំនួសធ្មេញច្រើនជាង 10 ដើម 3-3 អ្នកដែលសមត្ថភាពលីនៃត្រចៀកទាំងពីរ ក្លាយជាមិនអាចស្តាប់សំលេងខ្សោយបានពេលឃ្លាតចំងាយជាង 1 ម៉ែត្រ 4 អ្នកដែលសមត្ថភាពលីនៃត្រចៀក1 ក្លាយជាមិនអាចស្តាប់សំលេងនិយាយធម្មតាបានពេលឃ្លាតចំងាយឆ្ងាយជាង40 សង់ទីម៉ែត្រ 5 អ្នកដែលបន្សល់ទុកឆ្អឹងខ្នងវៀច 6 អ្នកដែលមានដៃ 1 បានបាត់ម្រាមចង្អុលដៃ ម្រាមដៃកណ្តាល ឬ ម្រាមដៃនាង 7 លុបចោល 8 អ្នកដែលមានជើង1បានបាត់តួនាទីម្រាមជើងលើសពី2រួមទាំងម្រាមជើងទី1 9 អ្នកដែលមានពិការភាពតួនាទីសរីរាង្គក្តុងទ្រូងឬពោះ ហើយមានការប៉ះពាល់ខ្លាំងពេលធ្វើការ
កំរិតទី 12	ដូចគ្នាចំនួន 156 ថ្ងៃ	1 អ្នកដែលមានការប៉ះពាល់ធ្ងន់ធ្ងរដល់តួនាទីតម្រូវឬប៉ះពាល់ដល់ចលនារបស់ត្រាប់ភ្នែក1 2 អ្នកដែលបន្សល់ទុកការប៉ះពាល់ធ្ងន់ធ្ងរដល់ចលនានៃត្របកភ្នែក1 3 អ្នកដែលបានទទួលការធ្វើជំនួសធ្មេញច្រើនជាង 7 ដើម 4 អ្នកដែលបានខូចខាតស្លឹកត្រចៀកអស់មួយភាគធំនៃត្រចៀក1 5 អ្នកដែលបានបន្សល់ទុកការវៀចធ្ងន់ធ្ងរដល់ ឆ្អឹងដងកាំបិត ឆ្អឹងដើមទ្រូង ឆ្អឹងជំនីរ ឆ្អឹងស្លាបប្រចៀវ ឬ ឆ្អឹងត្រគាក 6 អ្នកដែលមានការប៉ះពាល់តួនាទីសន្លាក់ធំនៃអវ:យវ:ខាងលើ1 ចំនួន1ក្នុងចំណោម3 7 អ្នកដែលមានការប៉ះពាល់តួនាទីសន្លាក់ធំនៃអវ:យវ:ខាងក្រោម1 ចំនួន1ក្នុងចំណោម3 8 អ្នកដែលបន្សល់ទុកការវៀចនៃឆ្អឹងវែង 8-2 អ្នកដែលបានបាត់កូនដៃនៃដៃ1 9 អ្នកដែលមានដៃ 1 បានបាត់តួនាទីម្រាមចង្អុលដៃ ម្រាមដៃកណ្តាល ឬម្រាមដៃនាង 10 អ្នកដែលបានបាត់បង់ម្រាមជើងទី2អ្នកដែលបានបាត់បង់ម្រាមជើងទី2រួមទាំងម្រាមជើងទី2 ឬអ្នកដែលបាត់បង់តួនាទីម្រាមជើង3ក្រៅពីម្រាមជើងទី3នៃជើង1

កំរិតពិការភាព	ខ្លឹមសារនៃការឧបត្ថម្ភ	ពិការភាពលើខ្លួនប្រាណ
		11 អ្នកដែលបាត់បង់ភ្នាទីម្រាមជើងទី1 ឬភ្នាទីម្រាមជើងទី4នៃជើង1 12 អ្នកដែលបានបន្សល់រោគសញ្ញាសរសៃប្រសាទខ្ពាំងតាមកន្លែង 13 លុបចេញ 14 អ្នកដែលបានបន្សល់ភាពអាក្រក់លើរូបរាងខាងក្រៅ
កំរិតទី13	ដូចគ្នាចំនួន 101 ថ្ងៃ	1 អ្នកដែលមានសមត្ថភាពមើលនៃភ្នែក1 នៅសល់ក្រោម 0.6 2 អ្នកដែលមានភ្នែក1មានភាពងងឹតមួយចំហៀង ដោយមានផ្នែកមើលឃើញតូចជាងមុនឬបន្សល់ទុកការខូចខាតកំហើញ 2-2 អ្នកដែលមើលឃើញបែកក្រៅពីមើលចំពីមុខ 3 អ្នកដែលមានការខូចខាតត្រាបកភ្នែកមួយផ្នែក ឬដាច់រោមភ្នែកទាំងពីរ 3-2 អ្នកដែលបានទទួលការធ្វើជំនួសធ្មេញច្រើនជាង 5 ដើម 3-3 អ្នកដែលមានការប៉ះពាល់ភ្នាទីសរីរាង្គក្នុងទ្រូងឬពោះ 4 អ្នកដែលមានកូនដៃបាត់បង់ភ្នាទីលើដៃ1 5 អ្នកដែលបានបាត់ផ្នឹងមេដៃមួយផ្នែកនៃដៃ1 6 លុបចេញ 7 លុបចេញ 8 អ្នកដែលអវ:យវ:ខាងក្រោម1 បានរួញលើសពី 1 សង់ទីម៉ែត្រ 9 អ្នកដែលបានបាត់ម្រាមជើង 1ឬ2រាប់ចាប់ពីម្រាមជើងទី3នៃជើង1

កំរិតពិការភាព	ខ្លឹមសារនៃការឧបត្ថម្ភ	ពិការភាពលើខ្លួនប្រាណ
កំរិតទី13		10 អ្នកដែលបានបាត់បង់ការប្រើប្រាស់ម្រាមជើងទី2 នៃជើង 1, ការប្រើម្រាមជើង2 រួមទាំងម្រាមជើងទី2 ឬអ្នកដែលបាត់បង់ការប្រើប្រាស់ម្រាមជើង3 ក្រៅពីម្រាមជើងធំ និងម្រាមជើងទី2
កំរិតទី14	ដូចគ្នាចំនួន 56 ថ្ងៃ	1 អ្នកដែលមានការខូចខាតត្រាបកភ្នែកមួយផ្នែក ឬដាច់រោមភ្នែកឆកលើភ្នែក1 2 អ្នកដែលបានទទួលការធ្វើជំនួសធ្មេញច្រើនជាង 3 ដើម 2-2 អ្នកដែលសមត្ថភាពលើនៃត្រចៀក1 ក្លាយជាមិនអាចស្តាប់សំលេងខ្ពាំងបានពេលឃ្លាតចំងាយឆ្ងាយជាង 1 ម៉ែត្រ 3 អ្នកដែលបន្សល់ស្នាមអាក្រក់ទំហំប៉ុនបាតដៃនៅកន្លែងមើលឃើញនៃអវ:យវ:ខាងលើ 4 អ្នកដែលបន្សល់ស្នាមអាក្រក់ទំហំប៉ុនបាតដៃនៅកន្លែងមើលឃើញនៃអវ:យវ:ខាងក្រោម 5 លុបចេញ 6 អ្នកដែលមានម្រាមដៃក្រៅពីមេដៃបានបាត់ផ្នឹងម្រាមដៃមួយផ្នែកលើដៃ1ចំហៀង 7 អ្នកដែលសន្លាក់ម្រាមដៃខាងចុងក្រៅពីមេដៃ លែងបត់បានលើដៃ1ចំហៀង 8 អ្នកដែលមានម្រាមជើង1ឬ2 បានបាត់បង់ភ្នាទីរាប់ពីម្រាមទី3 លើជើងណា1 9 អ្នកដែលបានបន្សល់រោគសញ្ញាសរសៃប្រសាទតាមកន្លែង 10 លុបចេញ

ផ្សេងៗ

1 របៀបវាស់សមត្ថភាពភ្នែក ធ្វើឡើងតាមការាងវាស់សមត្ថភាពជាសកល។ ចំពោះអ្នកដែលមិនអាចផ្តោតពន្លឺឲ្យត្រូវចំរ៉េទីនបាន គឺវាស់សមត្ថភាពភ្នែកកែតម្រូវ។

2 "អ្នកដែលបានបាត់ម្រាមដៃ" បានន័យថា "គឺអ្នកដែលបានបាត់លើសពីសន្លាក់ម្រាមដៃចំពោះមេដៃ លើសពីសន្លាក់កណ្តាលម្រាមដៃចំពោះម្រាមដៃផ្សេង"។

3 "អ្នកដែលមានម្រាមដៃបាត់បង់ភ្នាទី" គឺ "អ្នកដែលបានបាត់ផ្នឹងចុងម្រាមដៃលើសពីពាក់កណ្តាល" ឬ "អ្នកដែលមានការប៉ះពាល់ដល់ចលនា សន្លាក់គល់ម្រាមដៃឬសន្លាក់កណ្តាលម្រាមដៃ(សន្លាក់ចុងម្រាមដៃចំពោះមេដៃ)"

4 "អ្នកដែលបាត់ម្រាមជើង" គឺអ្នកដែលបានបាត់ម្រាមជើងនោះទាំងអស់។

5 "អ្នកដែលមានម្រាមជើងបាត់ភ្នាទី" គឺ "អ្នកដែលបានបាត់ផ្នឹងចុងម្រាមមេជើងលើសពីពាក់កណ្តាល ឬអ្នកដែលបានបាត់លើសពីសន្លាក់ចុងម្រាមជើងចំពោះជើងផ្សេង" ឬ "អ្នកដែលមានការប៉ះពាល់ដល់ចលនា សន្លាក់គល់ម្រាមជើង ឬសន្លាក់កណ្តាលម្រាមជើង(សន្លាក់ចុងម្រាមជើងចំពោះមេជើង)"។

សោធន៍និវត្តន៍(សំណង)ពិការភាពជាដើមបើកផ្តាច់ជាមុន

អាចទទួលបាន សោធន៍និវត្តន៍(សំណង)ពិការភាពជាដើម បើកផ្តាច់ជាមុនបានតែ1ដង

ខ្លឹមសារនៃការឧបត្ថម្ភ

ចំនួនទឹកប្រាក់សោធន៍និវត្តន៍បើកផ្តាច់ជាមុន ត្រូវបានកំណត់តាមកំរិតនៃពិការភាព អាចជ្រើសរើសជំរើសដែលប្រាថ្នាចង់បាន។ នៅពេលដែលប្រាក់បើកផ្តាច់ជាមុនត្រូវបានបង់ សោធន៍និវត្តន៍(សំណង)ពិការភាពជាដើម នឹងត្រូវបានបញ្ឈប់រហូតដល់ចំនួនសរុបនៃប្រាក់ប្រចាំខែ(ចំពោះប្រាក់ដែលហួសពីឆ្នាំទី1នឹងត្រូវផ្ទាត់ចេញដោយអត្រាការប្រាក់កំណត់ដោយច្បាប់) មានចំនួនស្មើនឹងចំនួនទឹកប្រាក់បើកផ្តាច់ជាមុន។

កំរិតពិការភាព		ចំនួនទឹកប្រាក់សោធន៍និវត្តន៍បើកផ្តាច់ជាមុន
កំរិតទី1	ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ	ចំនួន200ថ្ងៃ ចំនួន400ថ្ងៃ ចំនួន600ថ្ងៃ ចំនួន800ថ្ងៃ ចំនួន1,000ថ្ងៃ ចំនួន1,200ថ្ងៃ ចំនួន1,340ថ្ងៃ
កំរិតទី2	〃	ចំនួន200ថ្ងៃ ចំនួន400ថ្ងៃ ចំនួន600ថ្ងៃ ចំនួន800ថ្ងៃ ចំនួន1,000ថ្ងៃ ចំនួន1,190ថ្ងៃ
កំរិតទី3	〃	ចំនួន200ថ្ងៃ ចំនួន400ថ្ងៃ ចំនួន600ថ្ងៃ ចំនួន800ថ្ងៃ ចំនួន1,000ថ្ងៃ ចំនួន1,050ថ្ងៃ
កំរិតទី4	〃	ចំនួន200ថ្ងៃ ចំនួន400ថ្ងៃ ចំនួន600ថ្ងៃ ចំនួន800ថ្ងៃ ចំនួន920ថ្ងៃ
កំរិតទី5	〃	ចំនួន200ថ្ងៃ ចំនួន400ថ្ងៃ ចំនួន600ថ្ងៃ ចំនួន790ថ្ងៃ
កំរិតទី6	〃	ចំនួន200ថ្ងៃ ចំនួន400ថ្ងៃ ចំនួន600ថ្ងៃ ចំនួន670ថ្ងៃ
កំរិតទី7	〃	ចំនួន200ថ្ងៃ ចំនួន400ថ្ងៃ ចំនួន560ថ្ងៃ

នីតិវិធីស្នើរសុំ

ជាទូទៅនៅពេលស្នើរសុំ ប្រាក់ឧបត្ថម្ភ(សំណង)ពិការភាព សូមដាក់"ពាក្យស្នើរសុំសោធន៍និវត្តន៍សំណងពិការភាពជាដើម ឬសោធន៍និវត្តន៍ពិការភាពសម្រាប់អ្នកធ្វើការលើសពីមួយកន្លែង ឬសោធន៍និវត្តន៍ពិការភាពបើកផ្តាច់ជាមុន"(ទម្រង់ស្នើរសុំសោធន៍និវត្តន៍ លេខ 10) ទៅប្រធានការិយាល័យស្តង់ដារការងារដែលមានសមត្ថកិច្ច។ ប៉ុន្តែបើសិនជាក្នុងកំឡុងពេល1ឆ្នាំបន្ទាប់ពីថ្ងៃដែលបានទទួលការជូនដំណឹងអំពីការសំរេចផ្តល់ប្រាក់សោធន៍និវត្តន៍ ទោះបីជាបានទទួលសោធន៍និវត្តន៍(សំណង)ពិការភាពជាដើមរួចហើយក៏ដោយ ក៏អាចស្នើរសុំបានដែរ។ ក្នុងករណីនេះ អាចស្នើសុំបានក្នុងចន្លោះ គណនាដោយយកទឹកប្រាក់ខ្ពស់បំផុតសំរាប់កំរិតពិការភាពនិមួយៗ ដកចំនួនទឹកប្រាក់សរុបនៃសោធន៍និវត្តន៍ដែលត្រូវបានបង់រួចហើយ។

ការហួសកាលកំណត់

ចំណាំថាលក្ខន្តិក:នៃការកំណត់ការទាមទារសិទ្ធិសម្រាប់ពិការភាព (សំណង) ជាដើម ប្រាក់សោធននិវត្តន៍ដែលបង់ប្រាក់ជាមុនគឺ2ឆ្នាំបន្ទាប់ពីថ្ងៃបន្ទាប់ នៅពេលដែលជំងឺឬរបួសត្រូវបានព្យាបាល (រោគសញ្ញាមានស្ថេរភាព)។

សោធន៍និវត្តន៍(សំណង)ពិការភាពជាដើមបើកផ្តាច់សម្រាប់ចំនួនខុសគ្នា

ក្នុងករណីដែល នៅពេលអ្នកមានសិទ្ធិទទួល សោធន៍និវត្តន៍(សំណង)ពិការភាពជាដើមបានស្លាប់ ទឹកប្រាក់សរុបដែលបានបង់សម្រាប់ សោធន៍និវត្តន៍(សំណង)ពិការភាពជាដើមនិង សោធន៍និវត្តន៍(សំណង)ពិការភាពជាដើមបើកផ្តាច់ មានចំនួនតិចជាងចំនួនដែលត្រូវបានកំណត់សម្រាប់កំរិតពិការភាពនិមួយៗនោះ សោធន៍និវត្តន៍(សំណង)ពិការភាពជាដើមបើកផ្តាច់សម្រាប់ចំនួនខុសគ្នានឹងត្រូវបានផ្តល់។

ខ្លឹមសារនៃការឧបត្ថម្ភ

សោធន៍និវត្តន៍(សំណង)ពិការភាពជាដើមបើកផ្តាច់សម្រាប់ចំនួនខុសគ្នា គឺបានមកពីទឹកប្រាក់ដែលត្រូវបានកំណត់សម្រាប់កំរិតពិការភាពនីមួយៗ ដកទឹកប្រាក់សរុបដែលបានបង់សម្រាប់ សោធន៍និវត្តន៍(សំណង)ពិការភាពជាដើមបើកផ្តាច់។ ចំពោះប្រាក់សោធន៍និវត្តន៍ពិការភាពពិសេស ក៏មានប្រព័ន្ធបើកផ្តាច់សម្រាប់ចំនួនខុសគ្នាដូចសោធន៍និវត្តន៍(សំណង)ពិការភាពជាដើមដែរ។

កំរិតពិការភាព	សោធន៍និវត្តន៍(សំណង)ពិការភាពជាដើមបើកផ្តាច់សម្រាប់ចំនួនខុសគ្នា		ប្រាក់សោធន៍និវត្តន៍ពិការភាពបើកផ្តាច់សម្រាប់ចំនួនខុសគ្នា	
កំរិតទី1	ប្រាក់ឧបត្ថម្ភមូលដ្ឋានជាថ្ងៃ x	1,340 ថ្ងៃ	ប្រាក់គណនាមូលដ្ឋានជាថ្ងៃ x	1,340 ថ្ងៃ
កំរិតទី2	〃	1,190 ថ្ងៃ	〃	1,190 ថ្ងៃ
កំរិតទី3	〃	1,050 ថ្ងៃ	〃	1,050 ថ្ងៃ
កំរិតទី4	〃	920 ថ្ងៃ	〃	920 ថ្ងៃ
កំរិតទី5	〃	790 ថ្ងៃ	〃	790 ថ្ងៃ
កំរិតទី6	〃	670 ថ្ងៃ	〃	670 ថ្ងៃ
កំរិតទី7	〃	560 ថ្ងៃ	〃	560 ថ្ងៃ

- **ក្រួសារដែលអាចទទួលសោធន៍និវត្តន៍(សំណង)ពិការភាពជាដើមបើកផ្តាច់សម្រាប់ចំនួនខុសគ្នា**

  ក្រួសារដែលអាចទទួលសោធន៍និវត្តន៍(សំណង)ពិការភាពជាដើមបើកផ្តាច់សម្រាប់ចំនួនខុសគ្នាគឺក្រួសារដូចមានក្នុង (1) ឬ (2) អាទិភាពគឺតាមលំដាប់ពី (1) ទៅ (2) [ក្នុងចំណោមក្រួសារគឺតាមលំដាប់ (1) (2)]។

  (1)អ្នកដែលមានជីវភាពជាមួយគ្នានៅពេលអ្នកធ្វើការស្លាប់ មានដូចជា ប្តីប្រពន្ធ[រួមទាំងប្តីប្រពន្ធដែលមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ប៉ុន្តែជាក់ស្តែងមានទំនាក់ទំនងដូចប្តីប្រពន្ធ។ ចំពោះ (2) ក៏ដូចគ្នា] កូន ឪពុកម្តាយ ចៅ យាយតា បងប្អូនបង្កើត

  (2)ប្តីប្រពន្ធ កូន ឪពុកម្តាយ ចៅ យាយតា បងប្អូនបង្កើត ដែលមិនមានក្នុង (1)

នីតិវិធីស្នើរសុំ

សូមដាក់ពាក្យស្នើរសុំសោធន៍និវត្តន៍សំណងពិការភាពបើកផ្តាច់សម្រាប់ចំនួនខុសគ្នា ឬសោធន៍និវត្តន៍ពិការភាពបើកផ្តាច់សម្រាប់ចំនួនខុសគ្នាសម្រាប់អ្នកធ្វើការលើសពីមួយកន្លែង ឬសោធន៍និវត្តន៍ពិការភាពបើកផ្តាច់សម្រាប់ចំនួនខុសគ្នា (ទម្រង់ទី2នៃលេខ 37) ទៅប្រធានការិយាល័យសង្គមការងារដែលមានសមត្ថកិច្ច។ សូមភ្ជាប់ឯកសារខាងក្រោមជាមួយពាក្យស្នើរសុំ។

- **ឯកសារភ្ជាប់ចាំបាច់ត្រូវដាក់**

ករណី	ឯកសារភ្ជាប់
ឯកសារចាំបាច់ត្រូវភ្ជាប់	ឯកសារដែលអ្នកបញ្ជាក់ទំនាក់ទំនងរវាងអ្នកស្នើរសុំនិងអ្នកធ្វើការ ដូចជា លិខិតចំលងនៃអត្រានុគោលដ្ឋាន សៀវភៅគ្រួសារ ។ល។
ក្នុងករណីដែលមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ជាមួយអ្នកធ្វើការដែលស្លាប់ ប៉ុន្តែជាក់ស្តែងមានទំនាក់ទំនងដូចប្តីប្រពន្ធ	ឯកសារបញ្ជាក់ការពិតនោះ
ក្នុងករណីដែលជីវភាពត្រូវបានទ្រទ្រង់ដោយអ្នកធ្វើការដែលបានស្លាប់	ឯកសារបញ្ជាក់ការពិតនោះ

*ក្រៅពីនេះក្នុងករណីខ្លះតម្រូវអោយដាក់ឯកសារបន្ថែមក៏មាន។

ការហួសកាលកំណត់

ចំពោះសោធន៍និវត្តន៍(សំណង)ពិការភាពជាដើមបើកផ្តាច់សម្រាប់ចំនួនខុសគ្នា រាប់ចាប់ពីថ្ងៃបន្ទាប់ពីថ្ងៃដែលអ្នកធ្វើការមានគ្រោះថ្នាក់បានស្លាប់ បើរយៈពេល 5ឆ្នាំបានកន្លងផុតទៅនឹងហួសកាលកំណត់ លែងមានសិទ្ធិស្នើរសុំតទៅទៀត សូមប្រុងប្រយ័ត្ន។

ប្រាក់ឧបត្ថម្ភ(សំណង)គ្រួសារជាដើម ប្រាក់ធ្វើបុណ្យសពជាដើម(ប្រាក់ឧបត្ថម្ភសម្រាប់ធ្វើបុណ្យសព)

